Noted on back of 5 trial 2022/Jul/14

ភ្ជាប់ 14/07/22

230

17-5-22

Note on the back for drafting default

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
លេខ ៤០៣៤ "១១"
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៦៦៧
ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១
**សំណុំរឿងស៊ើបសួរ**
លេខ ៤៦៣
ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១
**ជំនុំជម្រះ**
លេខ ៣១១៥
ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១
វេលាម៉ោង ០២ និង ៣០ នាទី រសៀល សាលសវនាការទី៨ ជាន់ទី៥
ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**
លោក [redacted] ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ
**តំណាងអយ្យការ**
លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
**ក្រឡាបញ្ជីសវនាការ**
លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦៧ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖**

១-ឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា មុខរបរ ប្រធានក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD សាសនាគ្រិស្ត ទីកន្លែងកំណើតនៅរដ្ឋ KOGI ប្រទេសនីហ្សេរីយ៉ា ទីលំនៅមុនពេលឃាត់ខ្លួននៅបុរីសំបូរមាស [redacted] សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១១៣១ "ង១" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១)

២-ឈ្មោះ [redacted] សុភា ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិត្រពាំងស្វាយ ឃុំបល្ល័ង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅបុរី [redacted] ភូមិសំបូរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្តីឈ្មោះ [redacted] SUNDAY មានកូនចំនួន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ **ឆបោក និងសំអាតប្រាក់** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណធី អត្តលេខ ១២៨៤ ការិយាល័យមានទីស្នាក់ការនៅផ្សារទំនើបស៊ីធីម៉ល ជាន់ទី២ ផ្លូវមុន្នីរ៉េត សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ **ជា**មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] SUNDAY ។



Scanned with CamScanner

**អ្នកបកប្រែភាសាអង់គ្លេស** លោក [redacted] ឈុនហ៊័រ ជាអ្នកបកប្រែប្រចាំនៅសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ អង្គភាពជំនាញហិរញ្ញវត្ថុនៃនាយកដ្ឋានប្រឆាំងអាវរកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានទទួលរបាយការណ៍ប្រតិបត្តិការណ៍សង្ស័យរបស់ ឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៣ឆ្នាំ ដែលបានទទួលការផ្ទេរប្រាក់ចូលតាមរយៈធនាគារកម្ពុជាសាធារណៈ ចំនួនមួយលើក ដែលមានទឹកប្រាក់ចំនួន ២.៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារ កៀសហុកសិបពីរ) ដុល្លារអាមេរិក ពីឈ្មោះ MARIA HOLLINS ដែលមានប្រភពចេញមកពីប្រទេស អូស្ត្រាលី ។ ក្រោយមកនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ធនាគារកម្ពុជាសាធារណៈបានទទួលសារ SWIFT ពីធនាគារ BANK OF AMERICA របស់សហរដ្ឋអាមេរិកឱ្យបង្វែរប្រាក់ត្រលប់ទៅវិញ ដោយសារតែប្រតិបត្តិការខាងលើជាប្រតិបត្តិការក្លែងបន្លំ ប៉ុន្តែទឹកប្រាក់ទាំងអស់ត្រូវដកចេញពីគណនីហើយ ។ ក្រោយពីទទួលបានសារ SWIFT នាយកដ្ឋានប្រឆាំងអាវរកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបានបើកការស៊ើបអង្កេតបឋម និងឈានទៅដល់ការឃាត់ខ្លួនឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា និងឈ្មោះ [redacted] សុភា ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ តាមដីកាបញ្ជាឱ្យចូលខ្លួនលេខ ០៤៤ អ.យ.ធ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីបានសាកសួរ ឈ្មោះ [redacted] SUNDAY បានឆ្លើយថា ខ្លួនចូលមកព្រះរាជាណាចក្រកម្ពុជា ហើយបានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD និងមានគណនីផ្ទាល់ខ្លួនលេខ 000៨0៨៦៦0 របស់ធនាគារវឌ្ឍនៈអាស៊ី (ABA) ដោយទទួលប្រាក់ពីក្រៅប្រទេសជាច្រើនមានដូចជា ប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសនៅសហគមអឺរ៉ុប ។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] SUNDAY បានទទួលប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក ពីឈ្មោះ [redacted] MARIES ប៉ុន្តែឈ្មោះ [redacted] MARIES បានប្រាប់ថាឱ្យឈ្មោះ [redacted] SUNDAY យកប្រាក់ទាំងនេះទៅឱ្យឈ្មោះ [redacted] PHILLIP ស្នាក់នៅប្រទេសកម្ពុជា ។ ឈ្មោះ [redacted] SUNDAY ក៏ប្រគល់ប្រាក់ទាំងនេះតាមការណែនាំរបស់ឈ្មោ[redacted] MARIES នៅចំណុចផ្សារស្ទឹងមានជ័យថ្មី ចំណែក ឈ្មោះ [redacted] សុភា ត្រូវបានឈ្មោះ [redacted]OLLINS ដែលត្រូវជាបងប្អូនថ្លៃរបស់ឈ្មោះ [redacted] SUNDAY នៅប្រទេសអូស្ត្រាលីផ្ទេរប្រាក់ចំនួន ២.៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារ កៀសហុកសិបពីរ) ដុល្លារអាមេរិក ចូលក្នុងគណនីរបស់ឈ្មោះ [redacted] សុភា មែន ប៉ុន្តែពុំទាន់បានដកប្រាក់ផង ស្រាប់តែគណនីនេះត្រូវបានដកប្រាក់ចេញវិញ ។ ក្រោយមកឈ្មោះ [redacted] SUNDAY ធ្លាប់បានទទួលបានការផ្ទេរប្រាក់ពីអតិថិជន ឈ្មោះ [redacted] KIM ជនជាតិកូរ៉េខាងត្បូងសរុបចំនួន ៤៨០ (បួនរយប៉ែតសិប) ដុល្លារអាមេរិក ផងដែរ ដោយស្គាល់គ្នាតាមរយៈការបង្ហោះវេបសាយឈ្មោះ Go4WORD BUSSINESS .COM ហើយមានការទាក់ទងគ្នាតាមរយៈធនាគារឱ្យទៅជនជាប់ចោទ ដោយគោលបំណងដើម្បីបម្លែងប្រាក់នេះទៅជាផលប្រយោជន៍របស់ខ្លួន ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ២៨៤៧ អ.យ.ឈ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៣៨៧៨ "ង១" ជ.ដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយនៅតំណាក់កាលសមត្ថកិច្ចថា៖ ខ្លួនមកប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ២០១២ កាន់លិខិតឆ្លងដែនលេខ A50210441 ផុតសុពលភាពនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ និងទិដ្ឋាការស្នាក់នៅផុតសុពលភាពថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ ក្នុងគោលបំណង



Scanned with CamScanner

បង្រៀនអង់គ្លេសនៅសាលាប៉ៃលធី តាមរយៈវេបសាយដែលមានឈ្មោះ **បងធំ** ។ ខ្លួនបានឈប់បង្រៀនភាសាអង់គ្លេសនៅសាលាប៉ៃលធី ហើយបានជួបឈ្មោះ [redacted] សុភា នៅស្ថានីយ៍ប្រេងតូតាល់អូឡាំពិច ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ក៏បានជជែកគ្នាលេងក្នុងម៉ាតស្គាល់គ្នា ។ លុះស្គាល់គ្នាបានរយៈពេលប្រាំខែ ខ្លួនក៏សុំលេខទូរស័ព្ទរបស់ឈ្មោះ [redacted]សុភា ហើយក៏ឈានដល់ការរួមរស់ជាមួយគ្នាបានកូនចំនួន ០៣នាក់ រហូតដល់ខែតុលា ឆ្នាំ២០១៨ ក៏ចុះសំបុត្រអាពាហ៍ពិពាហ៍ ។ ខ្លួនបានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD នៅឆ្នាំ២០១៩ ដែលជាក្រុមហ៊ុនប្រឹក្សាយោបល់សម្រាប់វិស័យកសិកម្ម និងសេវាកម្ម មានអាសយដ្ឋាននៅបុរីសំបូរមាស ផ្ទះលេខ១៣ε ផ្លូវលេខ២១៧ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីណែនាំភ្ញៀវធ្វើកសិកម្មទូទៅ និងបានណែនាំភ្ញៀវប្រហែល ១០នាក់ ជាជនបរទេស ក្នុងនោះមានតែភ្ញៀវ ០៣នាក់តែប៉ុណ្ណោះ ដែលទទួលការប្រឹក្សាពីខ្លួនដោយបានទទួលកំរៃពីភ្ញៀវបរទេសចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅ ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ទៅតាមការងារតិច ឬច្រើន ។ ក្រុមហ៊ុនរបស់ខ្លួនមានច្បាប់អនុញ្ញាតត្រឹមត្រូវពីក្រសួងពាណិជ្ជកម្ម មានប័ណ្ណប៉ាតង់ឆ្នាំ២០១៩-២០២០ ។ ដោយឡែកបុគ្គលិកមានតែខ្លួនម្នាក់គត់ ហើយខ្លួនរកចំណូលបានពីការប្រឹក្សាយោបល់មិនទៀងទាត់ ដោយខែខ្លះរកកម្រៃពុំបាន ហើយខែខ្លះអាចរកបានកម្រៃប្រហែល ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ។ ខ្លួនបានបើកគណនីធនាគារ ០២ គឺនៅធនាគារកម្ពុជាសាធារណៈ (មិនចាំលេខ) បានបើកក្នុងអំឡុងខែឧសភា ឆ្នាំ២០១២ ក្នុងគោលបំណងដកប្រាក់ផ្ទាល់ខ្លួន និងទទួលប្រាក់បៀវត្សពីសាលាប៉ៃលធី ។ ខ្លួនបានទទួលការផ្ទេរប្រាក់ចូលពីក្រៅប្រទេស ២ ទៅ ៣លើក (មិនចាំថ្ងៃខែឆ្នាំ) លើកទី១ ចំនួន ១.៦៥០ (មួយពាន់ប្រាំមួយរយហាសិប) ដុល្លារអាមេរិក លើកទី២ និងចំនួន ២.២០០ (ពីរពាន់ពីររយ) ដុល្លារអាមេរិក ពីបងថ្លៃឈ្មោះ [redacted] HOLLINS ភេទស្រី នៅឆ្នាំ២០១៨ ក្នុងគោលបំណងជួយដោះស្រាយជីវភាពផ្ទាល់ខ្លួន និងលើកទី៣ ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ពីឈ្មោះ US MANDAUDA ភេទប្រុស ត្រូវជាបងប្អូនជីដូនមួយនៅប្រទេសអូស្ត្រាលី ក្នុងគោលបំណងធ្វើឱ្យក្រុមហ៊ុនផ្ទាល់របស់ខ្លួនឈ្មោះ APPROVE GLOBAL CO.,LTD ដំណើរការបានល្អ ។ ខ្លួនត្រូវការប្រាក់ចំនួន ៩៥០ (ប្រាំបួនរយហាសិប) ដុល្លារអាមេរិក ដើម្បីធ្វើប័ណ្ណប៉ាតង់ធ្វើអាជីវកម្ម ដោយឡែកប្រាក់ចំនួន ១.១០០ (មួយពាន់មួយរយ) ដុល្លារអាមេរិក សម្រាប់ក្រុមហ៊ុនបង់ពន្ធ និងទឹកប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក សម្រាប់ដាក់ក្នុងគណនីធនាគាររបស់ក្រុមហ៊ុនខាងលើ ។ គណនីធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) មានការផ្ទេរប្រាក់ចូលពីប្រទេសផ្សេងៗ ក្នុងនោះមានការផ្ទេរប្រទេសចិន របស់ឈ្មោះ [redacted]KWEE ភេទប្រុស សរុប ២.៧០០ (ពីរពាន់ប្រាំពីររយ) ដុល្លារអាមេរិក ផ្ទេរប្រាក់ពីអតិថិជន (មិនចាំឈ្មោះ) ជនជាតិអឺរ៉ុប ចំនួន ១.៧០០ (មួយពាន់ប្រាំពីរយ) ដុល្លារអាមេរិក និងផ្ទេរប្រាក់ពីអតិថិជន ឈ្មោះ [redacted]KIM (មិនចាំឈ្មោះពេញ) ជនជាតិកូរ៉េខាងត្បូង ភេទប្រុស សរុប ៤៨០ (បួនរយប៉ែតសិប) ដុល្លារអាមេរិក ។ នៅថ្ងៃទី០១ ខែកុម្ភៈ ២០២១ ខ្លួនបានទៅដកប្រាក់ពីធនាគារ ABA របស់ខ្លួនផ្ទាល់ជាង ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក អ្នកផ្ញើឱ្យឈ្មោះ [redacted] MARIES សញ្ជាតិប្រេស៊ីល ក្នុងគោលបំណងធ្វើអាជីវកម្ម ប៉ុន្តែដោយសារមានការយល់ច្រលំលើកិច្ចសន្យាបង្កឱ្យខ្លួន និងឈ្មោះ [redacted] MARIES មិនបានព្រមព្រៀងជាមួយគ្នាក្នុងការធ្វើអាជីវកម្មនេះ ពេលនោះឈ្មោះ [redacted]ARIES បានតម្រូវឱ្យខ្លួនយកប្រាក់ទាំងនោះទៅឱ្យមនុស្សម្នាក់ឈ្មោះ [redacted]PHILLIP ដែលខ្លួនមិនស្គាល់គ្នាពីមុន តែដឹងថាឈ្មោះ [redacted] PHILLIP នៅក្បែរផ្សារស្ទឹងមានជ័យថ្មី ។ ខ្លួនក៏រង់ចាំនៅទីនោះរួច ក៏មានបុរសម្នាក់បានដើរមកក្បែរខ្លួនថា ខ្លួនឈ្មោះ [redacted] PHILLIP លុយនៅឯណា? ពេលនោះខ្លួនក៏ប្រគល់ប្រាក់ទាំងនោះទៅគាត់ ([redacted]HILLIP) ។ ខ្លួនធ្លាប់បានឱ្យប្រពន្ធរបស់ខ្លួន ឈ្មោះ [redacted] សុភា ផ្ញើប្រាក់ទៅវិញតាមរយៈគណនី ABA របស់ប្រពន្ធខ្លួនផ្ញើទៅប្រទេសចិន ចំនួន ៨២០ (ប្រាំបីរយម្ភៃ) ដុល្លារអាមេរិក អ្នកទទួលឈ្មោះ [redacted]IANG និងផ្ញើទៅប្រទេសអ៊ីស្រាអែល ចំនួន ១.០៥០ ដុល្លារ (មួយពាន់ហាសិប) ដុល្លារអាមេរិក និងអ្នកទទួលមិនចាំឈ្មោះនៅប្រទេសអូស្ត្រាលី ចំនួន ២៨០ (ពីររយប៉ែតសិប) ដុល្លារអាមេរិក ដោយសារធ្វើការងារឱ្យអតិថិជនមិនបានសម្រេច ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] KWEE ឈ្មោះ [redacted]PATER និងឈ្មោះ [redacted]KIM តាមរយៈការបង្ហោះវេបសាយឈ្មោះ Go4WORD BUSSINESS.COM ហើយមានទំនាក់ទំនងគ្នាតាមរយៈវេបសាយនេះប៉ុណ្ណោះ ក្នុង



Scanned with CamScanner

គោលបំណងរកស៊ីខាងកសិកម្ម ។ ខ្លួនពុំមានឯកសារកិច្ចព្រមព្រៀងទេ ដោយសារខ្លួនបានបាត់ទូរស័ព្ទចាស់ ដោយបានថតឯកសារទាំងនោះទុកក្នុងទូរស័ព្ទ ។ ខ្លួនមិនមែនជាមេក្លោងទេ ព្រោះខ្លួនជាម្ចាស់ក្រុមហ៊ុនខាងលើផ្ទាល់ ហើយខ្លួនក៏ពុំមានបណ្តាញដែរ ដោយសារខ្លួនមិនមានទំនាក់ទំនងជាមួយអ្នកដទៃឡើយ ខ្លួនមិនធ្លាប់បានបញ្ជានរណាម្នាក់ឱ្យបើកគណនីធនាគារ សម្រាប់ទទួលប្រាក់នៅប្រទេសកម្ពុជាទេ ហើយខ្លួនក៏ពុំបានណែនាំឱ្យប្រពន្ធរបស់ខ្លួនទៅបើកគណនីធនាគារដែរ គឺប្រពន្ធរបស់ខ្លួនមានគណនីផ្ទាល់ខ្លួនរបស់គាត់ ។ នៅអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ មានគេផ្ទេរប្រាក់ចូលពីប្រទេសអឺរ៉ុប មិនដឹងប្រភពអ្នកផ្ញើ ដែលបានផ្ញើចូលមកប្រហែលចំនួន ៤.៧០០ (បួនពាន់ប្រាំពីររយ) ដុល្លារអាមេរិក ចូលក្នុងគណនី ABA របស់ប្រពន្ធខ្លួនឈ្មោ[redacted] សុភា ខ្លួនបានប្រាប់ប្រពន្ធថា មានគេផ្ទេរប្រាក់ចូលមកហើយ បន្ទាប់មកខ្លួនក៏បានប្រាប់ទៅប្រពន្ធទៀតថា បើសិនជាមានការផ្ទេរប្រាក់ចូលមកច្រលំរយៈពេលតែ ០១ ខែ ទៅ ០២ ខែ ប្រាក់នោះមិនបានផ្ទេរត្រលប់ទៅធនាគារដើមវិញទេ នោះគឺសំណាងរបស់អ្នកហើយ ក្រោយមកខ្លួននិងប្រពន្ធ ក៏បានទៅដកប្រាក់នោះមកប្រើប្រាស់ ប៉ុន្តែខ្លួនពុំស្គាល់អត្តសញ្ញាណអ្នកផ្ញើមកពីប្រទេសទេ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភា បានឆ្លើយនៅតំណាក់កាលសមត្ថកិច្ចថា៖ ខ្លួនធ្លាប់បម្រើការងារនៅអង្គការ CITY POINT ក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥ បន្ទាប់ពីខ្លួនបានស្គាល់បុរសឈ្មោះ [redacted] ([redacted] SUNDAY) អាយុ ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៤ នៅហាងម៉ាត នៅអូឡាំពិក ហើយបានទំនាក់ទំនងជាមួយគ្នាបានកូនចំនួន ០៣នាក់ នៅបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅឆ្នាំ២០១៨ ។ ខ្លួនបានបើកគណនីធនាគារចំនួន ០៥ តាមសំណូមពររបស់ឈ្មោះ[redacted] SUNDAY គឺ ១-ធនាគារកម្ពុជាសាធារណៈ គណនីលេខ ២៦០០២៣០០១៦២៦៨ បានបើកនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ សម្រាប់ទទួលប្រាក់ពីក្រៅប្រទេស គណនីនេះធ្លាប់មានបញ្ហាមួយលើក នៅពេលដែលប្តីរបស់ខ្លួនបានផ្តល់លេខគណនីនេះទៅឱ្យដៃគូរកស៊ីរបស់ប្តីខ្លួនខុស ទើបគេសុំឱ្យបង្វែរប្រាក់ចំនួន ២.៨០០ (ពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក ត្រលប់ទៅវិញ ដើម្បីផ្ទេរមកម្តងទៀត ឱ្យត្រឹមត្រូវតាមគណនីរបស់ខ្លួន ២-ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) គណនីលេខ ០០៥១៤៣១០ បានបើកក្នុងអំឡុងឆ្នាំ២០១៨ (មិនចាំថ្ងៃខែ) សម្រាប់រកស៊ីផ្ទាល់ខ្លួន ក្នុងនោះប្តីរបស់ខ្លួនធ្លាប់យកគណនីនេះផ្ទេរប្រាក់ចេញទៅប្រទេសចិនចំនួន ០១លើក សរុប ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក ផ្ទេរទៅប្រទេសអ៊ីស្រាអ៊ែល ០១លើក សរុប ១.០៥០ (មួយពាន់ហាសិប) ដុល្លារអាមេរិក និងផ្ទេរទៅប្រទេសអូស្ត្រាលី ០៣លើក ក្នុងមួយលើកៗសរុប ១៣០ (មួយរយសាមសិប) ដុល្លារអាមេរិក ព្រមទាំងខ្លួនបានដកប្រាក់ចំនួនជាង ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក នៅដើមខែមករា ឆ្នាំ២០២១ ដែលផ្ទេរមកពីក្រៅប្រទេសជាប្រាក់របស់មិត្តភក្តិរបស់ប្តីខ្លួន ក្រោយពេលដែលខ្លួនដកបានមិត្តភក្តិរបស់ប្តីខ្លួនបានយកមកដល់ផ្ទះ ខ្លួនបានដកប្រាក់មួយចំនួនទៀតពីចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ទៅ ១.០០០ (មួយពាន់) ដុល្លារអាមេរិក ៣-ធនាគារ J TRUST ROYAL បានបើកអំឡុងឆ្នាំ២០២០ (មិនចាំលេខ និងមិនចាំថ្ងៃខែ) គណនីនេះមិនធ្លាប់មានការផ្ទេរប្រាក់ចូលទេ ៤-ធនាគារ SACOM បើកអំឡុងឆ្នាំ២០២០ (មិនចាំលេខ និងមិនចាំថ្ងៃខែ) គណនីនេះខ្លួនធ្លាប់ឮប្តីរបស់ខ្លួននិយាយថាបានដកប្រាក់ចំនួន ០១លើក សរុប ២.០០០ (ពីរពាន់) ដុល្លារអាមេរិក និង ៥-ធនាគារ INDO CHINA បានបើកអំឡុងឆ្នាំ២០២០ (មិនចាំលេខ និងមិនចាំថ្ងៃខែ) គណនីនេះខ្លួនធ្លាប់ដកប្រាក់ចំនួន ០២លើក ដោយលើកទី០១ ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក និងលើកទី០២ សរុប ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ។ រាល់សៀវភៅធនាគារ និងកាត ATM ប្តីរបស់ខ្លួនជាអ្នកឱ្យបើកសម្រាប់ទទួលប្រាក់ពីក្រៅប្រទេសដើម្បីទទួលបានកម្រៃជើងសារ ១០% ដែលមិត្តភក្តិរបស់ប្តីខ្លួនផ្ញើមកពីក្រៅប្រទេស ទឹកប្រាក់ដែលខ្លួនបានដកសរុបចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ទៅ ៣០.០០០ (បីពាន់) ដុល្លារអាមេរិក បានប្រគល់ទៅឱ្យមិត្តភក្តិរបស់ប្តីខ្លួនជាអ្នកទទួលបន្ត ពេលខ្លួនមកយកដល់ផ្ទះ និងពេលខ្លះខ្លួនផ្ញើទៅឱ្យពួកគេ តាមធនាគារ WING ទឹកប្រាក់ទាំងអស់ដែលខ្លួនបានដកដោយសារប្តីរបស់ខ្លួនធ្វើចត្តាឡីស័ក ក្រោយពេលត្រលប់មកពីទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម នៅពាក់កណ្តាលខែមករា ឆ្នាំ២០២១ បន្ទាប់ពីប្តីរបស់ខ្លួនធ្វើចត្តាឡីស័កចប់ ប្តីរបស់ខ្លួនបានទៅដកប្រាក់០១លើក (មិនដឹងចំនួន) នៅចុងខែមករា ឆ្នាំ២០២១ និង ២ ទៅ ៣ថ្ងៃមុននេះ ។ ប្តីរបស់ខ្លួនដកប្រាក់ ចំនួន

០១លើក សរុបជាង ៣០.០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក ហើយមិត្តភក្តិរបស់ប្តីខ្លួនបានមកទទួលប្រាក់នេះដល់ផ្ទះជួលរបស់ខ្លួនផ្ទាល់ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយនៅតំណាក់កាលអយ្យការថា៖ ខ្លួនបានចូលមកប្រទេសកម្ពុជាដំបូងនៅអំឡុងឆ្នាំ២០១២ ក្នុងគោលបំណងធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស នៅក្នុងឆ្នាំ២០១៥ ។ ខ្លួនបានជួបប្រពន្ធខ្លួនឈ្មោះ [redacted] សុភា ហើយក៏បានរួមរស់ជាមួយគ្នា រហូតដល់មានកូន ០៣នាក់ ។ នៅក្នុងអំឡុងពេលដែលខ្លួនរស់នៅជាមួយប្រពន្ធខ្លួនមិនដែលត្រលប់ទៅប្រទេសនីហ្សេរីយ៉ានោះឡើយ ប៉ុន្តែនៅពេលលិខិតឆ្លងដែនខ្លួនផុតសុពលភាពនោះ ខ្លួនទៅស្នើសុំទិដ្ឋាការនៅប្រទេសថៃ និងរៀនជំនាញបន្ថែម ។ នៅពេលដែលខ្លួនបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD នេះ គឺខ្លួនបើកក្នុងគោលបំណងប្រឹក្សាវិស័យកសិកម្ម ជាមួយនឹងប្រទេសជាច្រើន មានដូចជា ប្រទេសចិន ប្រទេសកូរ៉េ និងប្រទេសនៅអឺរ៉ុប ។ ចំពោះគណនីធនាគារប្រចាំក្រុមហ៊ុនខាងលើ គឺខ្លួនបានបង្កើតនៅធនាគារ ABA ដោយដាក់ឈ្មោះក្រុមហ៊ុនផ្ទាល់តែម្តង ហើយមានតែខ្លួនម្នាក់ជាម្ចាស់ក្រុមហ៊ុនមានសិទ្ធិដក ដាក់ និងធ្វើប្រតិបត្តិការផ្សេងៗមិនពាក់ព័ន្ធនឹងប្រពន្ធរបស់ខ្លួនទេ ហើយប្រពន្ធខ្លួនក៏មិនមានតួនាទី ឬការងារអ្វីនៅក្រុមហ៊ុននេះដែរ ។ ចំពោះប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក ដែលឈ្មោះ [redacted] MARIES ភេទប្រុស សញ្ជាតិប្រេស៊ីល បានផ្ញើគណនីផ្ទាល់ចូលមកក្រុមហ៊ុនរបស់ខ្លួននេះ គឺដោយសារគាត់មានបំណងចង់ទិញដំឡូងបារាំង ខ្ទឹមខ្ទឹម នៅកម្ពុជារួចផ្ញើទៅទីក្រុងឌូបៃ ប៉ុន្តែក្រោយពីមានការព្រមព្រៀងគ្នាហើយ ស្រាប់តែឈ្មោះ [redacted] MARIES បានកែប្រែចិត្ត មិនចង់ទិញផលិតផលទាំងនោះទៀតទេ បែរជាបានបញ្ជាខ្លួនថា នៅពេលលុយធ្លាក់ចូលគណនីធនាគារខ្លួនហើយទៅដករួចចាំប្រគល់ឱ្យឈ្មោះ [redacted] PHILLIP ដែលកំពុងនៅប្រទេសកម្ពុជាទៅចាំ ឈ្មោះ [redacted] MARIES ជាអ្នកណាត់ឱ្យជួបគ្នា ។ មុនដកប្រាក់មួយថ្ងៃនោះឈ្មោះ [redacted] MARIES ក៏បានផ្ញើសារអេឡិចត្រូនិច (EMAIL) មកខ្លួនជាមុនថាឱ្យខ្លួនទៅចាំនៅមុំផ្សារស្ទឹងមានជ័យថ្មីទៅ ឈ្មោះ [redacted] PHILLIP នឹងមកជួបខ្លួននៅផ្សារស្ទឹងមានជ័យថ្មី ដើម្បីទទួលប្រាក់ទាំងនោះ ។ លុះស្អែកឡើងនៅវេលាម៉ោងប្រហែល ០៨ និង ៣០ នាទីយប់ ខ្លួនបានដកប្រាក់ ចំនួន ៣០.០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក នោះ ហើយទៅចាំឈ្មោះ [redacted] PHILLIP នៅផ្សារស្ទឹងមាន ជ័យថ្មី ដល់ពេលខ្លួនចាំគាត់ប្រហែល ៤៥នាទី ស្រាប់តែមានបុរសស្បែកស (ដូចពួកស្បែកសអឺរ៉ុប) អាយុប្រហែល៤០ឆ្នាំ រាងខ្ពស់ជាងខ្លួន បានមកប្រាប់ខ្លួនថាគាត់ [redacted] PHILLIP ប្រគល់លុយឱ្យគាត់លឿនមក ពេលនោះខ្លួនក៏ប្រគល់ឱ្យភ្លាមៗ មិនបាននិយាយអ្វីទេ ។ ពេលបានលុយហើយឈ្មោះ [redacted] PHILLIP ក៏និយាយដេញខ្លួនឱ្យទៅៗ ហើយខ្លួនក៏ចេញពីកន្លែងនោះមក ។ នៅអំឡុងឆ្នាំ២០១៨ ដោយសារពេលនោះជីវភាពក្រុមគ្រួសារខ្លួនលំបាកពេក មិនមានលុយផ្គត់ផ្គង់ជីវភាព ខ្លួនក៏បានពឹងពាក់ឈ្មោះ [redacted] HOLLINS ភេទស្រី អាយុប្រហែល៥០ឆ្នាំ សញ្ជាតិអូស្ត្រាលី ត្រូវជាបងស្រីថ្លៃខ្លួន រស់នៅប្រទេសអូស្ត្រាលី ដើម្បីសុំលុយខ្លះ ពេលនោះគាត់ក៏បានផ្ញើមកឱ្យពួកខ្លួនតាមគណនីធនាគារផ្ទាល់របស់ប្រពន្ធខ្លួនឈ្មោះ [redacted] សុភា នៅធនាគារកម្ពុជាសាធារណៈប្រហែលជាចំនួន ២.៨៥០ (ពីរពាន់ប្រាំបីរយហាសិប) ដុល្លារអាមេរិក ។ ពេលបងថ្លៃស្រីខ្លួនប្រាប់ថាគាត់បានផ្ញើហើយ ខ្លួន និងប្រពន្ធក៏ឆែកមើលគណនីទៅមិនឃើញឡើងទិន្នន័យក្នុងគណនីទេ ហេតុនេះខ្លួន និងប្រពន្ធគិតថាបងថ្លៃស្រីបានផ្ញើចូលគណនីហើយ ។ ពេលនោះខ្លួនក៏ទាក់ទងទៅបងស្រីថ្លៃ គាត់ក៏ទាក់ទងទៅធនាគារនៅប្រទេសគាត់ឱ្យធ្វើបែបបទបញ្ជូនប្រាក់នោះត្រលប់មកវិញ ជាហេតុធ្វើឱ្យខាងធនាគារនៅប្រទេសគាត់ផ្ញើសារមកធនាគារនៅកម្ពុជាតែម្តង ។ រំលងបាន ០២ថ្ងៃ ស្រាប់តែទឹកប្រាក់ចំនួន ២.៨៥០ (ពីរពាន់ប្រាំបីរយហាសិប) ដុល្លារអាមេរិក នោះបានចូលមកគណនីប្រពន្ធខ្លួនទៅវិញ ។ ខ្លួន និងប្រពន្ធទៅបើកប្រាក់គិតថាមិនមានបញ្ហាអ្វីតាមខ្លួនគិតដោយសារតែការទំនាក់ទំនងគ្នាមិនត្រូវបែបនេះបានជា BANK OF AMERICA



Scanned with CamScanner

មានការសង្ស័យចំពោះការផ្ញើប្រាក់មិនប្រក្រតី ក្រោយមានរឿងបែបនេះបងថ្លៃស្រីខ្លួន បានបិទគណនីដែលគាត់បានផ្ញើប្រាក់មកឱ្យពួកខ្លួនចោលបាត់ហើយ ។ ចំពោះប្រាក់ចំនួន ៤.៧០០ (បួនពាន់ប្រាំពីររយ) ដុល្លារអាមេរិក ដែលបានវេរចូលក្នុងគណនីធនាគារ ABA ផ្ទាល់ខ្លួនរបស់ប្រពន្ធខ្លួន ដោយមិនដឹងពីប្រភពច្បាស់នេះ ខ្លួនបានប្រាប់ប្រពន្ធខ្លួនថា ប្រសិនបើម្ចាស់ប្រាក់មិនបានសួរនាំទេ ។ រំលង ០១ ទៅ ០២ខែ យើងអាចដកបានហើយ ក្រោយមកមិនឃើញមានការសួរនាំ ខ្លួននិងប្រពន្ធក៏ដកយកមកចាយទៅ ខ្លួនសូមបញ្ជាក់បន្ថែមថាតាំងពីអំឡុងឆ្នាំ២០២១ ខ្លួនពុំមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនអ្វីទេ ចលនវត្ថុក៏គ្មាន រីឯផ្ទះសព្វថ្ងៃដែលបើកក្រុមហ៊ុននេះទៀត ក៏ខ្លួនជួលគេដែរ តែមានម៉ូតូ០១គ្រឿងទៀតរបស់ប្រពន្ធខ្លួនដែលខ្លួនយកមកជិះធ្វើដំណើរ ខ្លួនមានគណនីធនាគារ ABA លេខ ០០៨០៨៦៦០ ជាគណនីផ្ទាល់ខ្លួនរបស់ខ្លួនមានសល់ប្រាក់ចំនួន ៣០.៥៤០,៤០ (សាមសិបពាន់ ប្រាំរយសែសិប និងសែសិបសេន) ដុល្លារអាមេរិក ប្រាកដមែន។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនមកប្រទេសកម្ពុជា ឆ្នាំ២០១២ ដើម្បីមកបង្រៀនភាសាអង់គ្លេសនៅសាលាប៉ែលពី និងបានបើកគណនីធនាគារចំនួន ១ គឺធនាគារសាធារណៈ (មិនចាំលេខ) ដោយខ្លួនទុកចោលយូរពេក ត្រូវធនាគារបិទគណនីរបស់ខ្លួនតែម្តង ។ ខ្លួនបានស្គាល់ប្រពន្ធខ្លួននៅឆ្នាំ២០១៤ និងបានរួមរស់ជាមួយគ្នាមានកូនចំនួន ០៣នាក់ ។ ខ្លួនពុំដែលបានត្រលប់ទៅប្រទេសនីហ្សេរីយ៉ាវិញទេ តែខ្លួនធ្លាប់បានឡើងទៅបន្តទិដ្ឋាការនៅឯប្រទេសថៃ នៅក្នុងអំឡុងឆ្នាំ២០១៩ ខ្លួនបានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD នេះ ដោយមានឡាយសិនពីក្រសួងពាណិជ្ជកម្មត្រឹមត្រូវ ដើម្បីប្រឹក្សាវិស័យកសិកម្មជាមួយភ្ញៀវបរទេស ដែលមានទីតាំងក្នុងបុរីសំបូរមាស ផ្ទះលេខ១៣៤ ផ្លូវលេខ២១៧ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានជាច្រើនប្រទេសដូចជាកូរ៉េ ចិន អឺរ៉ុប ដោយមានតែខ្លួនតែម្នាក់ឯងជាម្ចាស់ក្រុមហ៊ុន ហើយខ្លួនបានបើកគណនីចំនួន០១ សម្រាប់ក្រុមហ៊ុននៅធនាគារ ABA ប៉ុន្តែខ្លួនមិនមានលេខគណនីនោះទេ ។ ដំបូងមានតម្កល់ប្រាក់ក្នុងនោះប្រហែល ៣.៨០០ (បីពាន់ប្រាំបីរយ) ដុល្លារអាមេរិក ទៅ ៣.៩០០ (បីពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ហើយបច្ចុប្បន្នប្រហែលនៅសល់តែចំនួន ៦០ (ហុកសិប) ដុល្លារអាមេរិក តែប៉ុណ្ណោះ ។ ប្រពន្ធខ្លួនឈ្មោះ [redacted] សុភា ពុំមានតួនាទីអ្វីនៅក្នុងក្រុមហ៊ុនខ្លួននោះទេ ។ ចំពោះប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ គឺឈ្មោះ RODRIGES MARIES ភេទប្រុស ជនជាតិប្រេស៊ីល នៅឯប្រទេសប្រេស៊ីល បានផ្ញើចូលគណនីផ្ទាល់ក្រុមហ៊ុនរបស់ខ្លួននេះ ព្រោះគេមានបំណងទិញ ដំឡូង បារាំង ខ្ញី ខ្ទឹម នៅកម្ពុជា រួចបញ្ជូនទៅទីក្រុងឌូបៃ តែក្រោយមកពុំមានការព្រមព្រៀងគ្នាវិញ ទើបឈ្មោះ [redacted] MARIES បញ្ជាឱ្យដកប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះយកទៅប្រគល់ឱ្យឈ្មោះ [redacted] PHILLIP ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាស្រាប់ ដោយឈ្មោះ [redacted] MARIES ជាអ្នកឱ្យខ្លួនទៅជួបជាមួយឈ្មោះ [redacted] PHILLIP នៅម្តុំផ្សារស្ទឹងមានជ័យថ្មី នៅនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៨ ទៅ ៩ យប់ និងបានប្រគល់ប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះទៅឱ្យឈ្មោះ [redacted] PHILLIP តែម្តង ។ នៅក្នុងឆ្នាំ២០១៨ ឈ្មោះ [redacted] HOLLINS ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិអូស្ត្រាលី ជាបងថ្លៃស្រីរបស់ខ្លួន បានផ្ញើប្រាក់មកឱ្យពួកខ្លួនចំនួន ២.៥៨០ (ពីរពាន់ប្រាំរយប៉ែតសិប) ដុល្លារអាមេរិក តាមរយៈគណនីរបស់ប្រពន្ធខ្លួននៅធនាគារកម្ពុជាសាធារណៈ (មិនចាំលេខ) ហើយឈ្មោះ [redacted] HOLLINS គាត់ផ្ញើច្រឡំចូលគេផ្សេង ទើបគាត់បានទាក់ទងធនាគារនៅអូស្ត្រាលីឱ្យប្រាក់នោះទៅវិញ ប៉ុន្តែខ្លួនប្រាប់ទៅគាត់ថា គាត់ផ្ញើចូលត្រឹមត្រូវហើយមិនបាច់ដកវិញទេ ទើបបាន២ថ្ងៃក្រោយមានទឹកប្រាក់ចំនួន ២.៥៨០ (ពីរពាន់ប្រាំរយប៉ែតសិប) ដុល្លារអាមេរិក ចូលក្នុងគណនីប្រពន្ធខ្លួន ហើយខ្លួន និងប្រពន្ធបានទៅដករួចរាល់អស់ហើយ



Scanned with CamScanner

ដោយសារ មានបញ្ហាទំនាក់ទំនងគ្នាមិនត្រូវនេះបានជា WEST PAC BANK មានការសង្ស័យថាមិនប្រក្រតី និងក្រោយមានរឿងបែបនេះ ទើបបងស្រីថ្លៃខ្លួនបានបិទគណនីធនាគាររបស់គាត់នៅប្រទេសអូស្ត្រាលីចោលហើយ ។ ចំពោះប្រាក់ចំនួន ៤.៧០០ (បួនពាន់ប្រាំពីរយ) ដុល្លារអាមេរិក បានវេរចូលក្នុងគណនីធនាគារកម្ពុជាសាធារណៈ (មិនចាំលេខគណនី) ផ្ទាល់ខ្លួនរបស់ប្រពន្ធខ្លួននៅអំឡុងឆ្នាំ២០១៧ ដោយមិនដឹងពីប្រភពច្បាស់នេះខ្លួនបានប្រាប់ប្រពន្ធខ្លួនថា ប្រសិនបើម្ចាស់ប្រាក់មិនបានសួរនាំទេ រំលង ០១ ទៅ ០២ ខែ យើងអាចដកបានហើយ ក្រោយមកមិនឃើញមានការសួរនាំខ្លួនក៏ដកយកទៅចាយទៅ ។ ក្នុងឆ្នាំ២០១៨ ធនាគារកម្ពុជាសាធារណៈ បានបិទគណនីធនាគាររបស់ប្រពន្ធខ្លួនក្រោយមានបញ្ហាជាមួយឈ្មោ[redacted]OLLINS ហើយប្រហែលនៅចុងឆ្នាំ២០១៨ ប្រពន្ធខ្លួនមានគណនីមួយទៀតនៅធនាគារ ABA (មិនចាំលេខ) សព្វថ្ងៃខ្លួនមានគណនីធនាគារចំនួន០២ គណនីរបស់ក្រុមហ៊ុន (មិនចាំលេខគណនី) និងរបស់ខ្លួនផ្ទាល់នៅធនាគារ ABA មានគណនីលេខ ០០០៨០៦៦០ ចំពោះបច្ចុប្បន្នទឹកប្រាក់នៅក្នុងគណនីផ្ទាល់ខ្លួនរបស់ខ្លួនមានចំនួន ៣០.៥៤០,៤០ (សាមសិបពាន់ ប្រាំរយសែសិប និងសែសិបសេន) ដុល្លារអាមេរិក ក្រោយពីគណនីធនាគារខាងលើនេះខ្លួនពុំមានទ្រព្យសម្បត្តិអ្វីទេ ហើយផ្ទះដែលខ្លួនបានរស់នៅគឺជួលពីគេទេ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]សុភា បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរថា៖ កន្លងមកថ្ងៃខែមិនចាំ ប្ដីខ្លួនបានឱ្យខ្លួនទៅដកប្រាក់ពីគណនីរបស់ខ្លួន (មិនចាំលេខ) នៅធនាគារ RHB ២លើក មួយលើកបានប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក តែខ្លួនពុំដឹងថាប្រភពលុយចូលមកពីណាឡើយ ព្រោះប្ដីខ្លួនជាអ្នកប្រើហើយភាគច្រើនគឺគាត់ជាអ្នកទៅបើក នៅក្នុងខែមករា ឆ្នាំ២០២១ ខ្លួនធ្លាប់បានទៅដកប្រាក់ពី គណនីរបស់ប្ដីខ្លួនតាមទូATM របស់ធនាគារ ABA ចំនួន ៥ដង មួយដងបានចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក សរុបទៅបានចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ដោយពេលនោះប្ដីខ្លួនធ្វើចត្តាឡីស័ក ។ ពេលបើកបានពីគណនីរបស់ខ្លួន និងរបស់ប្ដីខ្លួនសរុបចំនួន ២៦.០០០ (ម្ភៃប្រាំមួយពាន់) ដុល្លារអាមេរិក ហើយប្ដីខ្លួនប្រាប់ខ្លួនថាត្រូវប្រគល់ទៅឱ្យមិត្តភក្តិរបស់គាត់ជាជនជាតិនីហ្សេរីយ៉ា មិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល ៣០ឆ្នាំជាងនៅនឹងផ្ទះជួលរបស់ខ្លួនស្ថិតនៅបុរីសំបូរមាស ផ្ទះលេខ ២១៧ សង្កាត់ដង្កោ ខណ្ឌដង្កោ ហើយខ្លួនមិនដឹងថាជនជាតិនីហ្សេរីយ៉ានោះនៅទីណានោះទេ ប្ដីខ្លួនឈ្មោ[redacted] SUNDAY ពុំដែលប្រាប់ខ្លួនឱ្យដឹងពីប្រភពលុយទាំងនោះមកពីណានោះទេ ហើយខ្លួននៅតែផ្ទះមើលតែកូន និងទទួលបានប្រាក់ពីគាត់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ម្ដង ១០០ ដុល្លារ ម្ដង ៥០ដុល្លារ តែប៉ុណ្ណោះ ខ្លួនពុំដឹងថាគាត់ធ្លាប់បានដកប្រាក់បានចំនួនប៉ុន្មាននោះទ តែខ្លួនដឹងថាពីមុនមកគាត់ពុំដែលមានលុយកាក់ទេ គឺទើបតែមួយរយៈចុងក្រោយនេះទេ ដែលឃើញថា មានការដកប្រាក់នេះ។

-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានឆ្លើយថា៖ នៅក្នុងអំឡុងឆ្នាំ២០១៩ ខ្លួនបានបើកក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD នេះ ដោយមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មត្រឹមត្រូវ ដើម្បីផ្ដល់សេវាកម្មប្រឹក្សាយោបល់វិស័យកសិកម្មជាមួយភ្ញៀវបរទេស ដែលមានទីតាំងក្នុងបុរីសំបូរមាស ផ្ទះលេខ១៣៤ ផ្លូវលេខ២១៧ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ អតិថិជនរបស់ខ្លួន មានជាច្រើនប្រទេសដូចជាកូរ៉េ ចិន និងអឺរ៉ុប ដោយមានតែខ្លួនម្នាក់ឯងជាម្ចាស់ក្រុមហ៊ុន ។ ខ្លួនបានបើកគណនីចំនួន០១ សម្រាប់ក្រុមហ៊ុននៅធនាគារ ABA ។ ដំបូងខ្លួនតម្កល់ប្រាក់ក្នុងគណនីប្រហែល ៣.៨០០ (បីពាន់ប្រាំបីរយ) ដុល្លាររអាមេរិក ទៅ ៣.៩០០ (បីពាន់ប្រាំបួនរយ) ដុល្លាររអាមេរិក ហើយ បច្ចុប្បន្នប្រហែលនៅសល់តែចំនួន ៦០ (ហុកសិប) ដុល្លារអាមេរិក តែប៉ុណ្ណោះ ។ ប្រពន្ធខ្លួនឈ្មោះ[redacted]សុភា ពុំមានតួនាទីអ្វីនៅក្នុងក្រុមហ៊ុនខ្លួននោះទេ ។ ចំពោះប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះ នៅ

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ គឺឈ្មោះ [redacted]MARIES នៅឯប្រទេសប្រេស៊ីល បានផ្ញើចូលគណនីក្រុមហ៊ុនរបស់ខ្លួន ព្រោះគេមានបំណងទិញ ដំឡូង បារាំង ខ្ញី ខ្ទឹម នៅកម្ពុជា រួចបញ្ជូនទៅទីក្រុងឌូបៃ តែក្រោយមកពុំមានការព្រមព្រៀងគ្នាវិញ ទើបឈ្មោះ [redacted]MARIES បញ្ជាឱ្យដកប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះយកទៅប្រគល់ឱ្យឈ្មោះ [redacted] PHILLIP ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាស្រាប់ ដោយឈ្មោះ [redacted]MARIES ជាអ្នកឱ្យខ្លួនទៅជួបជាមួយឈ្មោះ [redacted]PHILLIP នៅម្តុំផ្សារស្ទឹងមានជ័យថ្មី នៅនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៨ ទៅ ៩ យប់ និងបានប្រគល់ប្រាក់ចំនួន ៣០.០០០ (សាមសិបពាន់) ដុល្លារអាមេរិក នោះទៅឱ្យឈ្មោះ [redacted]PHILLIP តែម្តង ។ នៅក្នុងឆ្នាំ២០១៨ ឈ្មោះ [redacted] HOLLINS ជនជាតិអូស្ត្រាលី ជាបងថ្លៃស្រីរបស់ខ្លួន បានផ្ញើប្រាក់មកឱ្យពួកខ្លួនចំនួន ២.៥៨០ (ពីរពាន់ប្រាំរយប៉ែតសិប) ដុល្លារអាមេរិក តាមរយៈគណនីរបស់ប្រពន្ធខ្លួននៅធនាគារកម្ពុជាសាធារណៈ (មិនចាំលេខ) ហើយឈ្មោះ [redacted] HOLLINS គាត់ផ្ញើច្រឡំចូលគេផ្សេង ទើបគាត់បានទាក់ទងធនាគារនៅអូស្ត្រាលីឱ្យផ្ទេរប្រាក់នោះទៅវិញ ។ ប៉ុន្តែខ្លួនប្រាប់ទៅគាត់វិញថា ការផ្ញើប្រាក់មកត្រឹមត្រូវហើយមិនបាច់ដកវិញទេ ទើប២ ថ្ងៃក្រោយមកអត់មានទឹកប្រាក់ចំនួន ២.៥៨០ (ពីរពាន់ប្រាំរយប៉ែតសិប) ដុល្លារអាមេរិក ចូលក្នុងគណនីប្រពន្ធខ្លួន ហើយខ្លួន និងប្រពន្ធបានទៅដករួចរាល់អស់ហើយ ។ ដោយសារមានបញ្ហាទំនាក់ទំនងគ្នាមិនត្រូវនេះបានជា WEST PAC BANK មានការសង្ស័យថាមានភាពមិនប្រក្រតី និងក្រោយមានរឿងបែបនេះ បងថ្លៃខ្លួនបានបិទគណនីធនាគាររបស់គាត់នៅប្រទេសអូស្ត្រាលីចោល ។ ចំពោះប្រាក់ចំនួន ៤.៧០០ (បួនពាន់ប្រាំពីររយ) ដុល្លារអាមេរិក បានផ្ទេរចូលក្នុងគណនីធនាគារកម្ពុជាសាធារណៈ (មិនចាំលេខគណនី) ផ្ទាល់ខ្លួនរបស់ប្រពន្ធខ្លួននៅអំឡុងឆ្នាំ២០១៧ ដោយមិនដឹងពីប្រភពច្បាស់នេះ ខ្លួនបានប្រាប់ប្រពន្ធខ្លួនថា ប្រសិនបើម្ចាស់ប្រាក់មិនបានសួរនាំទេ រំលង ០១ ទៅ ០២ ខែ យើងអាចដកបានហើយ ក្រោយមកមិនឃើញមានការសួរនាំខ្លួនក៏ដកយកទៅចាយទៅ ។ ក្នុងឆ្នាំ២០១៨ ធនាគារកម្ពុជាសាធារណៈ បានបិទគណនីធនាគាររបស់ប្រពន្ធខ្លួនក្រោយមានបញ្ហាជាមួយឈ្មោះ[redacted] HOLLINS ។ ប្រហែលនៅចុងឆ្នាំ២០១៨ ប្រពន្ធខ្លួនមានគណនីមួយទៀតនៅធនាគារ ABA (មិនចាំលេខ) ។ សព្វថ្ងៃខ្លួនមានគណនីធនាគារចំនួន០២ គណនីរបស់ក្រុមហ៊ុនមួយ និងគណនីផ្ទាល់ខ្លួនមួយនៅធនាគារ ABA ។ បច្ចុប្បន្នទឹកប្រាក់នៅក្នុងគណនីផ្ទាល់ខ្លួនរបស់ខ្លួនមានចំនួន ៣០.៥៤០,៤០ (សាមសិបពាន់ ប្រាំរយសែសិប និងសែសិបសេន) ដុល្លារអាមេរិក ។ ក្រៅពីគណនីធនាគារខាងលើនេះ ខ្លួនពុំមានទ្រព្យសម្បត្តិអ្វីទេ ហើយផ្ទះដែលខ្លួនរស់នៅជាផ្ទះជួលទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សុភា បានឆ្លើយថា ៖ កន្លងមកថ្ងៃខែមិនចាំ ប្តីខ្លួនបានឱ្យខ្លួនទៅដកប្រាក់ពីគណនីរបស់ខ្លួន (មិនចាំលេខ) នៅធនាគារ RHB ចំនួន ២ លើក មួយលើកបានប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក តែខ្លួនពុំដឹងថា ប្រភពលុយបានមកពីណាឡើយ តែភាគច្រើនគាត់ជាអ្នកទៅបើក ។ នៅក្នុងខែមករា ឆ្នាំ២០២១ ខ្លួនធ្លាប់បានទៅដកប្រាក់ពីគណនីធនាគាររបស់ប្តីខ្លួនតាមទូរ ATM របស់ធនាគារ ABA ចំនួន ៥ ដង ។ ក្នុងម្តងដកបានប្រាក់ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក សរុបទៅបានចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ព្រោះពេលនោះប្តីខ្លួនធ្វើចត្តាឡីស័ក ។ ពេលបើកបានពីគណនីសរុបចំនួន ២៦.០០០ (ម្ភៃប្រាំមួយពាន់) ដុល្លារអាមេរិក ប្តីខ្លួនក៏ប្រាប់ខ្លួនប្រគល់ទៅឱ្យមិត្តភក្តិរបស់គាត់ជាជនជាតិនីហ្សេរីយ៉ា មិនស្គាល់ឈ្មោះ ដោយប្រគល់នៅផ្ទះជួលរបស់ខ្លួនស្ថិតនៅបុរីសំបូរមាស ។ ខ្លួនមិនដឹងថាជនជាតិនីហ្សេរីយ៉ាខាងលើនៅទីណានោះទេ ហើយប្តីខ្លួនក៏ពុំដែលប្រាប់ខ្លួនឱ្យដឹងពីប្រភពលុយទាំងនោះមកពីណានោះទេ ។ ខ្លួននៅផ្ទះមើលតែកូន និងទទួលបានប្រាក់ពីគាត់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ម្តង ១០០ ដុល្លារ ម្តង ៥០ ដុល្លារ តែប៉ុណ្ណោះ ខ្លួនពុំដឹងថា គាត់ធ្លាប់បានដកប្រាក់បានចំនួនប៉ុន្មាននោះទេ ។ ខ្លួនគ្រាន់តែដឹងថាពីមុនមកគាត់ពុំដែលមានលុយទេ ហើយទើបតែមួយរយៈចុងក្រោយនេះទេ ដែលឃើញថា មានការដកប្រាក់នេះ ។ រាល់សៀវភៅធនាគារ និងកាត ATM ប្តីរបស់ខ្លួនជាអ្នកឱ្យបើកសម្រាប់ទទួលប្រាក់ពីក្រៅប្រទេសដើម្បីទទួលបានកម្រៃជើងសារ ១០% ដែលមិត្ត

ភក្តិរបស់ប្តីខ្លួនផ្ញើមកពីក្រៅប្រទេស ។ ទឹកប្រាក់ដែលខ្លួនបានដកសរុបចំនួន ៧០០ (ប្រាំពីររយ) ដុល្លារអាមេរិក ទៅ ៣០.០០០ (បីពាន់) ដុល្លារអាមេរិក បានប្រគល់ទៅឱ្យមិត្តភក្តិរបស់ប្តីខ្លួនជាអ្នកទទួលបន្ត ។ ពេលខ្លះមិត្តភក្តិប្តីខ្លួនមកយកដល់ផ្ទះ និងពេលខ្លះខ្លួនផ្ញើទៅឱ្យពួកគេ តាមធនាគារ WING ។ ទឹកប្រាក់ទាំងអស់ដែលខ្លួនបានដកដោយសារប្តីរបស់ខ្លួនធ្វើចត្តាឡីស័ក ក្រោយពេលត្រលប់មកពីទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម ។ នៅពាក់កណ្តាលខែមករា ឆ្នាំ២០២១ បន្ទាប់ពីបុតិរបស់ខ្លួនធ្វើចត្តាឡីស័កចប់ ប្តីរបស់ខ្លួនបានទៅដកប្រាក់០១លើក (មិនដឹងចំនួន) នៅចុងខែមករា ឆ្នាំ២០២១ និង ២ ទៅ ៣ថ្ងៃមុននេះ ។ ប្តីរបស់ខ្លួនដកប្រាក់ ចំនួន០១លើក សរុបជាង ៣០.០០០ (សាមសិបម៉ឺន) ដុល្លារអាមេរិក ហើយមិត្តភក្តិរបស់ប្តីខ្លួនបានមកទទួលប្រាក់នេះដល់ផ្ទះផ្ទាល់របស់ខ្លួនផ្ទាល់ដែរ ។

**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ**

ក្រោយពីបានសួរដេញដោល និងពិនិត្យឯកសារក្នុងសំណុំរឿងឃើញថា ជនជាប់ចោទឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា បាន **ឆបោក និង សម្អាតប្រាក់** ទង្វើនេះ បង្ហាញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ។ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរ ទុកជាបានការទាំងស្រុង និងស្នើសុំតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

ឆ្លងតាមការពិភាក្សាដេញដោលនាពេលសវនាការឃើញថា ប្រតិបត្តិការផ្ទេរប្រាក់ទាំងប៉ុន្មានគ្រាន់តែជាប្រាក់ក្នុងរបររកស៊ីអាជីវកម្មរបស់កូនក្តីខ្លួនតែប៉ុណ្ណោះដោយកូនក្តីខ្លួនបានផ្តល់សេវាកម្ម ដូចជា ការប្រឹក្សាយោបល់ និងទិញផលិតផលកសិកម្មទៅក្រៅប្រទេស ហើយកូនក្តីខ្លួនទទួលបានកម្រៃជើងសារលើទំនិញទាំងអស់នោះ ។ ដោយឡែកទឹកប្រាក់ដែលកូនក្តីខ្លួនបានដកចំនួន ២.៥៨០,៦២ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារ កៀសហុកសិបពីរ) ដុល្លារអាមេរិក កូនក្តីខ្លួនបានឆ្លើយរួចមកហើយថា ជាប្រាក់ដែលបងប្អូនថ្លៃជាអ្នកផ្ទេរមកឱ្យ តែដោយសារមានការខុសលេខគណនី ទើបមានការសួរដេញដោល និងឃាត់កូនក្តីខ្លួន ។ ចំពោះទឹកប្រាក់ដែលបានដកទាំងអស់ កូនក្តីខ្លួនឈ្មោះ [redacted] សុភា គឺមិនបានដឹងនោះទេ ហើយឈ្មោះ [redacted] SUNDAY ក៏បានឆ្លើយថា ប្រពន្ធរបស់គាត់ឈ្មោះ [redacted] សុភា មិនបានដឹងផងដែរ ។ ដូច្នេះ ខ្លួនសូមស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា រួចផុតពីបទចោទប្រកាន់ ពីបទល្មើស ឆបោក និងសម្អាតប្រាក់ ។

**សម្តីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] SUNDAY ស្នើសុំតុលាការបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] សុភា ស្នើសុំតុលាការឱ្យជួយរកយុត្តិធម៌ និងបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**



Scanned with CamScanner

១-កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ នៅព្រះរាជាណាចក្រកម្ពុជា (រាជធានីភ្នំពេញ) ជនជាប់ចោទឈ្មោះ [redacted] SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ និងឈ្មោះ [redacted] សុភា ភេទស្រី អាយុ ៣៣ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស ឆបោក និង សម្អាតប្រាក់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដូចបានលើកឡើងក្នុងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជម្រះលេខ ៣៨៧៨ "ង១" ដ.ដ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ចេញដោយចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ មែន ។

២-យោងតាមរបាយការណ៍លេខ ១៦៤/២១ រ.ប.ក.នបភកខ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ បានបង្ហាញថា កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ គណនីលេខ ២៦០០២៣០០១៦២៦៨ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** មានឈ្មោះ [redacted] សុភា ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីប្រទេសអូស្ត្រាលីចំនួន ២.៥៨០,៦២ $ ពីឈ្មោះ [redacted] Hollins ហើយក្រោយមកធនាគារបានស្នើសុំបង្វែរប្រាក់នោះត្រឡប់ទៅវិញ ដោយមូលហេតុថា ការផ្ទេរប្រាក់ខាងលើពាក់ព័ន្ធអំពើក្លែងបន្លំ ។

៣-តាមលិខិតចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់នៃគណនី **ធនាគារកម្ពុជាសាធារណៈ** ដែលមានគណនីលេខ ២៦០០២៣០០១៦២៦៨ មានឈ្មោះ [redacted] សុភា ជាម្ចាស់គណនីឃើញថា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ពិតជាមានប្រតិបត្តិការផ្ទេរប្រាក់ចូលពីប្រទេសអូស្ត្រាលីចំនួន ២.៥៨០,៦២ $ មែន ។ បន្ទាប់ពីទឹកប្រាក់ទាំងនេះបានផ្ទេរចូលក្នុងគណនីខាងលើរួច ទឹកប្រាក់ទាំងនេះត្រូវបានដកចេញយ៉ាងឆាប់រហ័ស នៅថ្ងៃទី២៩ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ។

៤-បើទោះបីជាជនជាប់ចោទឈ្មោះ [redacted] SUNDAY បានបដិសេធថា ប្រាក់ចំនួន ២.៥៨០,៦២ $ ដែលផ្ទេរពីបរទេសពុំមែនកើតឡើងដោយសារអំពើឆបោក ហើយជាប្រាក់ដែលសាច់ញាតិជនជាប់ចោទឈ្មោះ [redacted] HOLLINS ផ្ញើមកដើម្បីចំណាយបើកក្រុមហ៊ុន តុលាការយល់ឃើញថា គ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវតែប៉ុណ្ណោះ ។ ជាក់ស្តែង ជនជាប់ចោទមិនមានភស្តុតាងណាមួយបញ្ជាក់ថា ឈ្មោះ [redacted] HOLLINS ជាសាច់ញាតិនោះទេ ហើយកន្លងមកក៏មិនមានឈ្មោះ [redacted] HOLLINS ផ្តល់សក្ខីកម្មដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទនោះដែរ ។ ជាងនេះទៀត ប្រសិនបើពិនិត្យទៅលើប្រតិបត្តិការណ៍ផ្ទេរប្រាក់ពីប្រទេសអូស្ត្រាលីមកគណនីធនាគាររបស់ជនជាប់ចោទឃើញថា មិនមានប្រតិបត្តិការណ៍ណាមួយដែលគូសបញ្ជាក់អំពីការចំណាយដូចដែលជនជាប់ចោទបានលើកឡើងនោះឡើយ ។ ប្រាក់ដែលបានផ្ទេរមកពីប្រទេសអូស្ត្រាលីចំនួន ២.៥៨០,៦២ $ ពីឈ្មោះ [redacted] Hollins ត្រូវបានជនជាប់ចោទដកភ្លាមៗបន្ទាប់ប្រាក់បានចូលទៅក្នុងគណនីធនាគារ ហើយការទាមទារឱ្យប្រទេសត្រឡប់ទៅវិញដោយម្ចាស់ប្រាក់មិនបានជោគជ័យនោះទេ ដែលចំណុចនេះផ្ទុយទៅនឹងអ្វីដែលជនជាប់ចោទបានអះអាងថា សាច់ញាតិរបស់ជនជាប់ចោទមានការភាន់ច្រឡំគណនីទើបស្នើសុំឱ្យផ្ទេរប្រាក់ត្រឡប់ទៅវិញ ហើយបន្ទាប់មកទើបសាច់ញាតិរបស់ជនជាប់ចោទផ្ទេរប្រាក់មកជាថ្មីម្តងទៀត ។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ឃើញថា ក្រៅអំពីប្រតិបត្តិការណ៍សង្ស័យខាងលើ ចាប់តាំងពីពេលជនជាប់ចោទបានបើកក្រុមហ៊ុន APPROVE GLOBAL Co.ltd បញ្ហាពាក់ព័ន្ធទៅនឹងការផ្ទេរប្រាក់នេះមិនមែនកើតឡើងជាលើកទីមួយនោះទេ ហើយកន្លងមកក៏ធ្លាប់មានការទាមទារប្រាក់ត្រឡប់ទៅវិញជាញឹកញាប់ផងដែរ ។ បើទោះបីជាជនជាប់ចោទបានអះអាងថា ការផ្ទេរប្រាក់ត្រឡប់ទៅវិញនេះដោយសារតែទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនរបស់ជនជាប់ចោទមិនជោគជ័យ ប៉ុន្តែជនជាប់ចោទមិនមានភស្តុតាងដើម្បីបញ្ជាក់



Scanned with CamScanner

អំពីប្រតិបត្តិការណ៍អាជីវកម្មរបស់ខ្លួននោះទេ ។

៦-ជនជាប់ចោទឈ្មោ[redacted] SUNDAY ក៏បានអះអាងផងដែរថា ក្នុងចំណោមប្រាក់ដែលបានផ្ទេរមកពីបរទេសមួយចំនួនជាប្រាក់ពាក់ព័ន្ធទៅនឹងទំនាក់ទំនងអាជីវកម្មរបស់ជនជាប់ចោទ ។ ប៉ុន្តែជាក់ស្តែងនៅក្នុងប្រតិបត្តិការណ៍ផ្ទេរប្រាក់នានាឃើញថា មិនមានប្រតិបត្តិការណ៍ណាមួយគួសបញ្ជាក់ពាក់ព័ន្ធទៅនឹងអាជីវកម្មប្រឹក្សាយោបល់សម្រាប់ វិស័យកសិកម្ម និងសេវាកម្មដូចដែលជនជាប់ចោទបានលើកឡើងនោះទេ ។ ក្រុមហ៊ុន APPROVE GLOBAL CO.,LTD ត្រូវបានបង្កើតឡើងដោយមានការចុះបញ្ជីត្រឹមត្រូវ ប៉ុន្តែពុំមានបុគ្គលិកបំពេញការងារនោះទេ ហើយទីតាំងចុះបញ្ជីក្រុមហ៊ុនក៏ពុំឃើញមានការលើកផ្លាកយីហោឱ្យបានត្រឹមត្រូវដើម្បីបញ្ជាក់អំពីអាជីវកម្មនេះដែរ ។

៧-យោងតាមរបាយការណ៍លេខ ១៦៨២៩ អពជ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ចេញដោយអគ្គនាយកដ្ឋានពន្ធដារលើក្រុមហ៊ុន APPROVE GLOBAL CO.,ltd ឃើញថា ក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,ltd ត្រូវបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារដើម្បីប្រកបមុខរបរប្រឹក្សាយោបល់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ។ ចាប់តាំងពីក្រុមហ៊ុននេះបានចុះបញ្ជីនៅឆ្នាំ២០១៩ រហូតមក ក្រុមហ៊ុនប្រកាសបង់តែពន្ធប៉ាតង់ និងពន្ធកាត់ទុកលើថ្លៃឈ្នួលការិយាល័យប៉ុណ្ណោះ ដោយពុំបានប្រកាសចំណូល ពីអាជីវកម្មប្រចាំខែ និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនោះឡើយ ។ ហេតុដូចនេះ អគ្គនាយកដ្ឋានពន្ធដារយល់ឃើញថា ក្រុមហ៊ុនពុំមានចំណូលអាជីវកម្មឡើយ ។ ចំណុចទាំងអស់នេះនាំឱ្យតុលាការយល់ឃើញថា ក្រុមហ៊ុន APPROVE GLOBAL CO., LTD របស់ជនជាប់ចោទគ្រាន់តែជាក្រុមហ៊ុនសំបក ហើយមិនមានប្រតិបត្តិការណ៍អាជីវកម្មអ្វីនោះទេ ។

៨-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ឃើញថា ជនជាប់ចោទបានដឹងថា មានការផ្ទេរប្រាក់ពីបរទេសចូលក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] សុភា ហើយជនជាប់ចោទថែមទាំងបានណែនាំឱ្យឈ្មោះ [redacted] សុភា ចាត់ចែងប្រាក់ទាំងនោះ ប្រសិនបើពុំមានការទាមទារត្រឡប់ទៅវិញ ។ បើទោះបីជាជនជាប់ចោទបានបដិសេធថា ជនជាប់ចោទមិនបានដឹងថាប្រាក់ទាំងនោះបានមកពីអំពើឆបោក តុលាការយល់ឃើញថា ជនជាប់ចោទគ្រាន់តែឆ្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ុភា ឃើញថា ជនជាប់ចោទមិនដែលបានចាត់ចែងនូវប្រាក់ទាំងអស់នេះនោះទេ ដោយជនជាប់ចោទគ្រាន់តែបានដក និងយកប្រាក់នេះទៅប្រគល់ទៅអ្នកផ្សេងទៀតតាមការណែនាំរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ប៉ុណ្ណោះ ។ សូម្បីតែគណនីធនាគារ ជនជាប់ចោទក៏បានបើកដើម្បីចាំតែទទួលប្រាក់ពីបរទេសតាមការណែនាំរបស់ជនជាប់ចោទឈ្មោះ [redacted]UNDAY ដែរ ។

៩-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានបញ្ជាក់ថា ជនជាប់ចោទមានបំណងក្នុងការប្រកាសពន្ធដែរ ប៉ុន្តែនាពេលជនជាប់ចោទកំពុងរៀបចំធ្វើការប្រកាសពន្ធក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន តែម្តង ។ ស្របតាមរបាយការណ៍ចេញដោយអគ្គនាយកដ្ឋានពន្ធដារខាងលើឃើញថា កន្លងមកជនជាប់ចោទក៏ធ្លាប់ប្រកាសពន្ធជូនអគ្គនាយកដ្ឋានពន្ធដារដែរ ដោយគ្រាន់តែជនជាប់ចោទធ្វើការប្រកាសតែពន្ធប៉ាតង់ និងពន្ធកាត់ទុកលើថ្លៃឈ្នួលការិយាល័យប៉ុណ្ណោះ ។ ហេតុដូចនេះ តុលាការចម្លើយរបស់ជនជាប់ចោទគ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ និងមិនអាចឱ្យតុលាការជឿជាក់បានឡើយ ។ ប្រសិនបើជនជាប់ចោទមានបំណងប្រកាសពន្ធលើប្រាក់ចំណូលមែននោះ ជនជាប់ចោទប្រាកដជាធ្វើការប្រកាសព្រមជាមួយពន្ធប៉ាតង់ និងពន្ធកាត់ទុកខាងលើ ហើយមិនមានហេតុផលដែលជនជាប់ចោទធ្វើការប្រកាសពន្ធនាពេលផ្សេងគ្នានោះទេ ។

១០-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានដឹងជាស្រេចថា ប្រាក់ដែលបានផ្ទេរមក

Scanned with CamScanner

ពីបរទេសចូលគណនីធនាគារមានការពាក់ព័ន្ធទៅនឹងបទល្មើស ទើបសកម្មភាពដែលជនជាប់ចោទឈ្មោះ [redacted] SUNDAY បានស្តែងឱ្យឃើញនូវផែនការដែលមានការរៀបចំ ។ ដើម្បីលាក់បំបាំងនូវអត្តសញ្ញាណពិតរបស់ខ្លួនជនជាប់ចោទបានប្រើប្រាស់អត្តសញ្ញាណរបស់ឈ្មោះ [redacted] សុភា ដើម្បីបើកគណនីធនាគារទទួលប្រាក់ជំនួស ។ ដើម្បីបំភាន់នូវប្រតិបត្តិការណ៍ផ្ទេរប្រាក់ពីបរទេស ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានបើកនូវក្រុមហ៊ុនឈ្មោះ APPROVE GLOBAL Co.ltd ជាក្រុមហ៊ុនសំបកដើម្បីទទួលប្រាក់ក្នុងរូបភាពជាអាជីវកម្ម ។ តាមរយៈចម្លើយបដិសេធនានារបស់ជនជាប់ចោទដែលមិនស៊ីសង្វាក់ទៅនឹងអង្គហេតុ និងមិនមានសំអាងច្បាស់លាស់នាំឱ្យតុលាការយល់ឃើញថា ជនជាប់ចោទមានចេតនាលាក់បាំងនូវអង្គហេតុនៃអំពើល្មើស ។

១១-ជនជាប់ចោទឈ្មោះ [redacted] សុភា បើទោះបីជាបានបដិសេធថា ជនជាប់ចោទមិនបានចូលរួម និងមិនមានការពាក់ព័ន្ធទៅនឹងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted]SUNDAY ដែលត្រូវជាប្តី តុលាការយល់ឃើញថា គ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវ ។ ជនជាប់ចោទស្ថិតក្នុងស្ថានភាពបានដឹងអំពីមុខរបរ និងការងាររបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY ។ សូម្បីតែគណនីធនាគារក៏ជនជាប់ចោទបើកដើម្បីចាំតែទទួលប្រាក់តាមការណែនាំរបស់ឈ្មោះ [redacted] SUNDAY ។ ជនជាប់ចោទក៏មិនមានទំនាក់ទំនងអាជីវកម្ម ឬការរកស៊ីណាមួយដែលជាមូលហេតុនាំឱ្យមានការផ្ទេរប្រាក់មកប្រទេសកម្ពុជានោះដែរ ។ នៅរាល់ពេលដែលជនជាប់ចោទដកប្រាក់ និងប្រគល់ប្រាក់ទៅអ្នកផ្សេងតាមការណែនាំរបស់ឈ្មោះ [redacted] SUNDAY ជនជាប់ចោទ ដកប្រាក់ចាប់ពី ៧០០ ដុល្លារអាមេរិក ទៅ ១.០០០ ដុល្លារអាមេរិក ទៅតាមចំនួនទឹកប្រាក់ដែលបានផ្ទេរមក ។

១២-ជារួម តាមរបាយការណ៍សំយោគ ចម្លើយរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ដែលបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា ពិតជាមានការព្រមព្រៀងដោយផ្ទាល់ធ្វើសកម្មភាពបន្លំចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលដោយប្រើប្រាស់នូវឧបាយកលទុច្ចរិត ហើយតាមរយៈអំពើនេះជនរងគ្រោះបានធ្វើការផ្ទេរប្រាក់ជាបន្តបន្ទាប់មកជនជាប់ចោទ ។ អំពើរបស់ជនជាប់ចោទដែលបានរៀបរាប់ខាងលើ បានប្រព្រឹត្តផ្ទុយទៅនឹងបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ ដែលបាន បញ្ញត្តិថា៖

*“**អំពើឆបោក** គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬ របស់តតិយជននូវការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ការផ្តត់ផ្គង់សេវា ការធ្វើ លិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ”*

១៣-តាមលិខិតលេខ ABALGD២១.០៦.៤៤៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារលេខ ០០១ ២៥២៤០៤ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** មាន **ក្រុមហ៊ុនឈ្មោះ** APPROVE GLOBAL CO.,LTD ជាម្ចាស់គណនីបានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ចំនួន ២៤ លើក សរុបជាប្រាក់ចំនួន ១៣៧.១៦៣,៥៥ $ (មួយរយសាមសិបប្រាំពីរពាន់ និង មួយរយហុកសិបបីដុល្លាររអាមេរិក ហាសិបប្រាំសេន) ។

១៤-តាមលិខិតលេខ ABALGD២១.០៦.៤៤៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារ



Scanned with CamScanner

លេខ ០០០៨០៨៦៦០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** មានជនជាប់ចោទឈ្មោ[redacted] SUNDAY ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ចំនួន ០២ លើក សរុបជាប្រាក់ចំនួន ១.២៨៣,៣៣ $ (មួយពាន់ ពីររយប៉ែតសិបបី ដុល្លារអាមេរិក និងសាមសិបបីសេន) ។

១៥-តាមលិខិតលេខ ABALGD២១.០៦.៤៤៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារលេខ០០០៥១៤៣១០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** មានឈ្មោះ[redacted] **សុភា** ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ចំនួន ៣ លើក សរុបជាប្រាក់ចំនួន ៨.៦៤២,៩៨ $ (ប្រាំបីពាន់ ប្រាំមួយរយសែសិបពីរដុល្លារអាមេរិក និងកៅសិបប្រាំបី) ។

១៦-តាមលិខិតលេខ RHR/COM/2021-051 ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ ចេញដោយ **ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារលេខ ២០១០០១១០០០០២១៨៣១ ចេញដោយ **ធនាគារធនាគារ អ អេច ប៊ី** មានឈ្មោះ[redacted] **សុភា** ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១៨ដល់ឆ្នាំ២០២១ ចំនួន ០៨ លើក សរុបជាប្រាក់ចំនួន ១៤.៩១១,២៧ $ (ដប់បួនពាន់ ប្រាំបួនរយដប់មួយ ដុល្លារអាមេរិក និងម្ភៃប្រាំពីរសេន) ។

១៧-តាមលិខិតចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារលេខ ២៦០០២៣០០១៦២៦៨ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** មានឈ្មោះ[redacted] **សុភា** ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ ចំនួន ០១ លើក សរុបជាប្រាក់ចំនួន ២.៥៨០,៦២ $ (ពីរពាន់ប្រាំរយប៉ែតសិបដុល្លារអាមេរិក និងហុកសិបពីរសេន) ។

១៨-តាមលិខិតចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រតិបត្តិការផ្ទេរប្រាក់ឃើញថា ជនជាប់ចោទតាមរយៈគណនីធនាគារលេខ ១៥០០២៣០០០៨០៨៧ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** មានឈ្មោះ [redacted] SUNDAY ជាម្ចាស់គណនី បានទទួលការផ្ទេរប្រាក់ពីបរទេសចាប់ពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៩ ចំនួន ០៧ លើក សរុបជាប្រាក់ចំនួន ៣៥.៦៥៨,០២ $ (សាមសិបប្រាំពាន់ ប្រាំមួយរយហាសិបប្រាំបីដុល្លារអាមេរិក និងសូន្យពីរសេន) ។

១៩-ជារួម ទឹកប្រាក់ផ្ទេរពីបរទេសចូលទៅក្នុងគណនីធនាគារដែលកាន់កាប់ដោយជនជាប់ចោទសរុបមានចំនួន **២០០.២៣៩,៧៧ $** (ពីររយពាន់ និងពីររយសាមសិបប្រាំបួន ដុល្លារអាមេរិក ចិតសិបប្រាំពីរសេន) ។ ក្នុងនោះគណនីដែលមានឈ្មោះ [redacted] SUNDAY ជាម្ចាស់គណនី មានទឹកប្រាក់ផ្ទេរចូលសរុបចំនួន **៣៦.៩៤១,៣៥ $** (សាមសិបប្រាំមួយពាន់ ប្រាំបួនរយសែសិបមួយ ដុល្លារអាមេរិក និងសាមសិបប្រាំសេន) គណនីដែលមានឈ្មោះ[redacted] **សុភា** ជាម្ចាស់គណនី មានទឹកប្រាក់ផ្ទេរចូលសរុបចំនួន **២៦.១៣៤,៨៧ $** (ម្ភៃប្រាំមួយពាន់ មួយរយសាមសិបបួន ដុល្លារអាមេរិក និង ប៉ែតសិបប្រាំពីរសេន) និងគណនីដែលមានក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO.,LTD ជាម្ចាស់គណនី មានទឹកប្រាក់ផ្ទេរចូលចំនួន **១៣៧.១៦៣,៥៥ $** (មួយរយសាមសិបប្រាំពីរពាន់ មួយរយហុកសិបបី ដុល្លារអាមេរិក និងហាសិបប្រាំសេន) ។

២០-ស្របតាមសំអាងហេតុចាប់ពីចំណុចលេខ២ ដល់ចំណុចលេខ ១២ នៃសេចក្ដីសម្រេច តុលាការរកឃើញថាប្រាក់ដែលផ្ទេរពីបរទេសចូលមកគណនីធនាគារដែលគ្រប់គ្រងដោយជនជាប់ចោទ សុទ្ធតែជាផលនៃបទល្មើសដែលកើត



Scanned with CamScanner

ចេញពីអំពើល្មើស ។ ដូចនេះ ប្រាក់សរុបចំនួន ២០០.២៣៩,៧៧ $ (ពីររយពាន់ ពីររយសាមសិបប្រាំបួន ដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) ជាប្រាក់ដែលមិនមានប្រភពច្បាស់លាស់ ឬជាផលនៃបទល្មើស ដែលជនជាប់ចោទបានទទួល ។

២១-តាមសំអាងហេតុចំណុចលេខ ២ ដល់ចំណុចលេខ ២០ នៃសេចក្តីសម្រេច តុលាការរកឃើញថា ផលនៃបទល្មើសដែលបានផ្ទេរពីបរទេសចូលមកគណនីធនាគារដែលកាន់កាប់ដោយជនជាប់ចោទសរុបមានចំនួន ២០០.២៣៩,៧៧ $ (ពីររយពាន់ ពីររយសាមសិបប្រាំបួនដុល្លារអាមេរិក និងចិតសិបប្រាំពីរសេន) ។ ក្នុងចំណោមផលនៃបទល្មើសទាំងអស់នេះ ប្រាក់ចំនួន ១២.០៨១,៨១$ (ដប់ពីរពាន់ ប៉ែតសិបមួយដុល្លារអាមេរិក និងប៉ែតសិបមួយសេន) ជនជាប់ចោទបានផ្ទេរទៅបរទេស ប្រាក់សរុបចំនួន ៣០.៥៩៧,២៦$ (សាមសិបពាន់ និងប្រាំរយកៅសិបប្រាំពីរដុល្លារអាមេរិក ម្ភៃប្រាំមួយសេន) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទ ។ ចំណែកប្រាក់ផ្សេងទៀតត្រូវបានជនជាប់ចោទផ្ទេរតាមរយៈគណនីធនាគារក្នុងស្រុក និងជាចុងក្រោយដកជាសាច់ប្រាក់យកទៅចាត់ចែងបាត់អស់ តែម្តង ។

២២-ក្នុងចំណោមប្រាក់ដែលជាផលនៃបទល្មើសបន្សល់ទុកក្នុងគណនីធនាគារ កាន់កាប់ដោយជនជាប់ចោទសរុបចំនួន ៣០.៥៩៧,២៦$ (សាមសិបពាន់ និងប្រាំរយកៅសិបប្រាំពីរដុល្លារអាមេរិក ម្ភៃប្រាំមួយសេន) ប្រាក់ចំនួន **៣០.៥៤០,៥៥ $** (សាមសិបពាន់ ប្រាំរយសែសិបដុល្លារអាមេរិក និងហាសិបប្រាំសេន) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] **SUNDAY** ប្រាក់ចំនួន **៤៨,០៧$** (សែសិបប្រាំបីដុល្លារអាមេរិក សូន្យប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] សុភា និងប្រាក់ចំនួន **៨.៦៤$** (ប្រាំបីដុល្លារអាមេរិក និងហុកសិបបួនសេន) ទៀតបន្សល់ទុកនៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO., LTD ។

២៣-យោងតាមរបាយការណ៍លេខ ៩១៨/២១ របក.នបភក.ឱ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ចេញដោយនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយមានភ្ជាប់មកជាមួយរបាយការណ៍សាច់ប្រាក់នៅក្នុងគណនីធនាគារដែលជាកម្មវត្ថុនៃការបង្កក និងរបាយការណ៍របស់ធនាគារឯកជនឃើញថា ប្រាក់ចំនួន ៣០,៥៤០.៥៥ (សាមសិបពាន់ និងប្រាំរយសែសិបដុល្លារអាមេរិក ហាសិបប្រាំសេន) បន្សល់ទុកនៅក្នុងគណនីធនាគារដែលមានលេខ ០០០៨០៨៦៦០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ។

២៤-យោងតាមរបាយការណ៍លេខ ៩១៨/២១ របក.នបភក.ឱ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ចេញដោយនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយមានភ្ជាប់មកជាមួយរបាយការណ៍សាច់ប្រាក់នៅក្នុងគណនីធនាគារដែលជាកម្មវត្ថុនៃការបង្កក និងរបាយការណ៍របស់ធនាគារឯកជនឃើញថា ក្នុងចំណោមប្រាក់ចំនួន **៤៨,០៧** (សែសិបប្រាំបី ដុល្លារអាមេរិក និងសូន្យប្រាំពីរ) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ [redacted] សុភា ប្រាក់ចំនួន ០,០៣ (សូន្យក្បៀស និងសូន្យបីសេន) បន្សល់ទុកនៅក្នុងគណនីធនាគារដែលមានលេខ ០០០៥១៤៣១០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ប្រាក់ចំនួន ១៦,៣៧ (ដប់ប្រាំមួយដុល្លារអាមេរិក និងសាម សិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារដែលមានលេខ ២០១០០១០០០០២១៨៣១ ចេញដោយ **ធនាគារ អ អេច ប៊ី** ប្រាក់ចំនួន ១០,០០$ (ដប់ដុល្លារអាមេរិក) បន្សល់ទុកនៅក្នុងគណនីធនាគារដែលមានលេខ ៤៣៩០០២៩ ចេញដោយ **ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់** ប្រាក់ចំនួន ១១,៦៧$ (ដប់មួយដុល្លារអាមេរិក និងហុកសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារដែលមានលេខ ២៦០០២៣០០១៦២៦៨ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** និងប្រាក់ចំនួន ១០ $ (ដប់ដុល្លារអាមេរិក) បន្សល់ទុកក្នុងគណនីធនាគារដែលមានលេខ ០៨០០០០៩៥៣៨៥០ ចេញដោយ **ធនាគារសាខមប៊ែង** ។

២៥-យោងតាមរបាយការណ៍លេខ ៩១៨/២១ របក.នបភក.ឱ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ ចេញដោយនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយមានភ្ជាប់មក



Scanned with CamScanner

ជាមួយរបាយការណ៍សាច់ប្រាក់នៅក្នុងគណនីធនាគារដែលជាកម្មវត្ថុនៃការបង្កក និងរបាយការណ៍របស់ធនាគារឯកជន ឃើញថា ប្រាក់ចំនួន ៨,៦៤ (ប្រាំបីដុល្លារអាមេរិក និងហុកសិបបួនសេន) បន្សល់ទុកក្នុងគណនីរបស់ ក្រុមហ៊ុន APPROVE GLOBAL CO., LTD ដែលមានគណនីលេខ ០០១២៥២៤០៤ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ។

២៦-ដើម្បីស្វែងរកផលនៃបទល្មើសដែលបានបាត់បង់ កន្លងមកចៅក្រមស៊ើបសួរបានចាត់ឱ្យនាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនបំពេញកិច្ចការស្រាវជ្រាវស្វែងរកទ្រព្យសម្បត្តិជាផលដែលកើតឡើងក្នុងអំឡុងពេលប្រព្រឹត្តបទល្មើសតាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ២១៦ "ង១" ព្រ.ទ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ។ ជាលទ្ធផល រហូតមកដល់បច្ចុប្បន្ននេះ នាយកដ្ឋានប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៅតែពុំមានរបាយការណ៍អំពីទ្រព្យសម្បត្តិរបស់ជនជាប់ចោទក្រៅពីគណនីធនាគារផ្តល់ជូនមកអាជ្ញាធរតុលាការ ។

២៧-តាមរបាយការណ៍លេខ ១៦៨២៩ អពជ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] SUNDAY និង ក្រុមហ៊ុន APPROVE GLOBAL CO.,ltd មិនមានព័ត៌មានអត្តសញ្ញាណកម្មអចលនទ្រព្យណាមួយ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារឡើយ ។

២៨-តាមដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ០២ "ង១" ដ.ប.ទ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ និងលេខ ០៩ "ង១" ដ.ប.ទ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ឃើញថា គណនីលេខ ០០០៨០៨៦៦០ ចេញដោយធនាគារ វឌ្ឍនៈអាស៊ីចំកាត់ (ABA) និង គណនីលេខ ១៥០០២៣០០០៨០៨៧ ចេញដោយធនាគារកម្ពុជាសាធារណៈ (Campu Bank) មានឈ្មោះ [redacted] SUNDAY ជាម្ចាស់គណនី និងគណនីលេខ ២៦០០២៣០០០១៦២៦៨ ចេញដោយធនាគារកម្ពុជាសាធារណៈ (Campu Bank) មានឈ្មោះ [redacted] សុភា ជាម្ចាស់គណនី ត្រូវបានចៅក្រមស៊ើបសួរសម្រេចបង្កកនូវគណនី និងប្រាក់ដែលមានក្នុងគណនីទាំងនេះដើម្បីធានាថា ទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស ឬមានការពាក់ព័ន្ធទៅនឹងបទល្មើសត្រូវបានរក្សាទុកដើម្បីជាកម្មវត្ថុនៃការរឹបអូស ។

២៩-តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៥០ រ.ប.ត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញឃើញថា ទ្រព្យសម្បត្តិដែលបន្សល់ទុកដោយជនជាប់ចោទឈ្មោះ [redacted] SUNDAY រួមមាន៖ ១-ទូរស័ព្ទដៃម៉ាក Olitech ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ) ២-ទូរស័ព្ទដៃម៉ាក SUMSUNG G8 PLUS ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ) ៣-ខ្សែកលោហធាតុ ពណ៌លឿងចំនួន ០១ ខ្សែ និង ៤-នាឡិការដៃម៉ាក DIESEL ពណ៌ទឹកមាស ចំនួន ០១គ្រឿង (មិនដំណើរការ) ។ ទ្រព្យសម្បត្តិទាំងនេះត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចាប់យក និងត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ ដើម្បីធានាដល់ការរឹបអូសនាពេលក្រោយ ។

៣០-តាមចម្លើយសារភាព ជនជាប់ចោទឈ្មោះ [redacted] សុភា បានទទួលស្គាល់ថា ជនជាប់ចោទបានបើកគណនីធនាគារចំនួនប្រាំ (ធនាគារកម្ពុជាសាធារណៈ ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ធនាគារជេត្រាស់រ៉ូយ៉ាល់ ធនាគារសាខមប៉ែង និងធនាគារ អេអេចប៊ី) ដើម្បីតែទទួលការផ្ទេរប្រាក់ពីបរទេសតាមការណែនាំរបស់ឈ្មោះ [redacted] SUNDAY ប៉ុណ្ណោះ ។ នៅក្នុងចំណោមប្រាក់ដែលជនជាប់ចោទដកបាន ជនជាប់ចោទបានប្រគល់ទៅឱ្យជនមិនស្គាល់តាមការណែនាំរបស់ឈ្មោះ [redacted] SUNDAY តាមរយៈធនាគារ តាមរយៈ Wing ឬប្រគល់ផ្ទាល់នៅផ្ទះជួលរបស់ជនជាប់ចោទ តែម្តង ។ នៅក្នុងទំនាក់ទំនងនេះ ជនជាប់ចោទឈ្មោះ [redacted] SUNDAY ជាអ្នកបានទទួលកម្រៃចំនួន ១០% (ដប់) ភាគរយ ។

៣១-តាមចម្លើយសារភាព ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានទទួលស្គាល់ថា ជន



Scanned with CamScanner

ជាប់ចោទពិតជាបានទទួលសាច់ប្រាក់ដែលបានផ្ទេរពីបរទេសចូលក្នុងគណនីធនាគាររបស់ឈ្មោះ [redacted] សុភា ម៉ែន ។ ទឹកប្រាក់ទាំងនេះ ជនជាប់ចោទបានប្រគល់ទៅឱ្យមិត្តភក្តិខ្លួនជាជនជាតិនីហ្សេរីយ៉ាខ្លះ និងបានផ្ទេរចេញទៅបរទេសវិញខ្លះ ។ នៅក្នុងប្រតិបត្តិការនេះ ជនជាប់ចោទបានទទួលស្គាល់ថា ជនជាប់ចោទបានទទួលកម្រៃចំនួន ១០% (ដប់) ភាគរយ ។

៣២-ជនជាប់ចោទឈ្មោះ [redacted] SUNDAY បានបដិសេធថា ប្រាក់ដែលបានផ្ទេរមកមួយចំនួនជាចំណូលក្នុងក្រុមហ៊ុន APPROVE GLOBAL CO.,LTD របស់ជនជាប់ចោទបានផ្តល់សេវាប្រឹក្សាយោបល់សម្រាប់វិស័យកសិកម្ម និងសេវាកម្ម ទៅអតិថិជនដែលជាជនបរទេស ចំណែកការផ្ទេរចេញ និងផ្ទេរចូលពីបរទេសវិញ គឺជាការរកស៊ីរបស់ខ្លួនតែប៉ុណ្ណោះ ជនជាប់ចោទមិនបានដឹងថាប្រាក់ដែលបានផ្ទេរនោះជាលុយកខ្វក់ មានប្រភពមិនស្របច្បាប់ ឬជាផលនៃបទល្មើសនោះទេ ។ ចំពោះចម្លើយបដិសេធនេះ តុលាការយល់ឃើញថា គ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវតែប៉ុណ្ណោះ ។ ជនជាប់ចោទឈ្មោះ [redacted] SUNDAY មានគណនីធនាគារផ្ទាល់ខ្លួនដែរ តែបែរជាណែនាំឱ្យជនជាប់ចោទឈ្មោះ [redacted] សុភា បើកគណនីធនាគារដើម្បីទទួលប្រាក់ផ្ទេរចូល និងផ្ទេរចេញទៅបរទេសទៅវិញ ។ ជនជាប់ចោទក៏ស្ថិតក្នុងស្ថានភាពដែលអាចនឹងដឹងដែរថា ពុំមានការងារដែលទទួលបានកម្រៃជើងសាររហូតដល់ទៅ ១០% ដោយគ្រាន់តែទៅដកប្រាក់ដើម្បីប្រគល់ទៅឱ្យម្ចាស់ប្រាក់ នោះទេ ។ ប៉ុន្តែដោយហេតុថា ជនជាប់ចោទទទួលបានកម្រៃ ១០% ជនជាប់ចោទបានបណ្តែតបណ្តោយមិនព្យាករអំពីបច្ច័យដែលកើតចេញពីអំពើរបស់ខ្លួន ។ ហេតុដូចនេះ តុលាការចាត់ទុកថា ជនជាប់ចោទក៏បានដឹងជាមុនផងដែរថា ប្រាក់ដែលបានផ្ទេរពីបរទេសចូលគណនីធនាគាររបស់ជនជាប់ចោទសុទ្ធតែជាផលនៃបទល្មើស ។

៣៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា ដែលទទួលប្រាក់ផ្ទេរពីបរទេស ដែលខ្លួនដឹងថាប្រាក់ទាំងនោះជាផលនៃបទល្មើស រួចធ្វើសកម្មភាពប្រគល់ និងផ្ទេរប្រាក់ទាំងនោះជាបន្តបន្ទាប់ ពិតជាមានគោលបំណងបិទបាំងប្រភពស្របច្បាប់នៃប្រាក់ទាំងនោះ ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុភា ដែលបានចូលរួមសកម្មភាពរបស់ឈ្មោះ [redacted] SUNDAY ទាំងដែលខ្លួនស្ថិតក្នុងស្ថានភាពដែលអាចដឹងថាប្រាក់ទាំងនោះជាផលនៃបទល្មើស មានគោលបំណងបិទបាំងប្រភពមិនស្របច្បាប់នៃប្រាក់ទាំងនោះ ។ ជារួមអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា ដែលបានលើកឡើង បានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិមាត្រា ៣ **កថាខណ្ឌទី១ ចំណុច ក** នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានបញ្ញត្តិអំពីនិយមន័យនៃការសម្អាតប្រាក់ថា៖

*"ការសម្អាតប្រាក់សំដៅដល់ ការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិដោយដឹងថា ទ្រព្យសម្បត្តិនេះជាផលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើសដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន ។"*

សកម្មភាពខាងលើ ក៏បានផ្ទុយផងដែរទៅនឹងបញ្ញត្តិមាត្រា ៣ **កថាខណ្ឌទី១ ចំណុចឃ** នៃច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានបញ្ញត្តិអំពីនិយមន័យនៃការសម្អាតប្រាក់ទៀតថា៖

*"ការសម្អាតប្រាក់សំដៅដល់ ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយ និងជំរុញ និងជម្រុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របកថាខណ្ឌទី១ នៃមាត្រា ៣ នៃច្បាប់នេះ ។"*

បទល្មើសសម្អាតប្រាក់ត្រូវបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

៣៤-ជនជាប់ចោទឈ្មោះ [redacted] SUNDAY និងឈ្មោះ [redacted] សុភា នាពេលប្រព្រឹត្តបទ



Scanned with CamScanner

ល្មើសស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ចំពោះអំពើរបស់ខ្លួន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៣៥-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការមានភាពសមហេតុផលគ្រប់គ្រាន់គប្បីតុលាការលើកយកមកពិចារណា ។ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនមានសំអាងគ្រប់គ្រាន់មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

៣៦-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]SUNDAY និងឈ្មោះ[redacted]សុភា ពីបទ **ឆបោក** និង **សំអាតប្រាក់** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្ដីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

៣៧-វត្ថុចាប់យកដូចជា៖ លិខិតឆ្លងដែនលេខ A៥០២១០៤៤១ ចំនួន ០១ (មួយ) ក្បាល និងសៀវភៅការងារជនបរទេស របស់ជនជាប់ចោទឈ្មោះ [redacted]SUNDAY ចំនួន ០១ (មួយ) ក្បាល មិនមានការពាក់ព័ន្ធទៅនឹងបទល្មើស គប្បីប្រគល់ជូនម្ចាស់ដើមវិញ ។

៣៨-វត្ថុចាប់យកដូចមានរៀបរាប់ក្នុងសំអាងហេតុលេខ ២៨ នៃសេចក្ដីសម្រេចនេះជាឧបករណ៍ ឬមធ្យោបាយប្រព្រឹត្តបទល្មើស និងជាផលនៃបទល្មើសគប្បីតុលាការសម្រេចរឹបអូស ។ ប្រាក់ចំនួន ៣០.៥៩៧,២៦ ដុល្លារអាមេរិក ដែលរក្សាទុកក្នុងគណនីធនាគារ និងត្រូវបានចៅក្រមស៊ើបសួរបង្កករួចរាល់ក៏ជាផលនៃបទល្មើស គប្បីតុលាការសម្រេចរឹបអូស ។

៣៩-ជនជាប់ចោទឈ្មោះ [redacted] សុភា មានការសោកស្ដាយទៅនឹងកំហុសរបស់ខ្លួន ហើយបានឆ្លើយសារភាពនូវអង្គហេតុនានាដែលបង្កលក្ខណៈងាយស្រួលដល់ការស្វែងរកការពិត ។ ជនជាប់ចោទឈ្មោ[redacted]សុភា បានជ្រុលប្រព្រឹត្តបទល្មើសដោយសារការអប់រំមានកម្រិត និងដោយការអូសទាញរបស់ឈ្មោះ [redacted]UNDAY ។ ក្នុងស្ថានភាពបច្ចុប្បន្ន ជនជាប់ចោទឈ្មោះ [redacted]សុភា មានកូនជាអនីតិជនចំនួនបីនាក់ ដែលត្រូវបីបាច់ថែរក្សា ។ ជនជាប់ចោទឈ្មោះ [redacted] SUNDAY ដែលត្រូវជាឪពុកបង្កើតអនីតិជនទាំងបីក៏កំពុងស្ថិតក្នុងការឃុំខ្លួនដើម្បីរងចាំការអនុវត្តទោស ។ ការកំណត់ឱ្យជនជាប់ចោទឈ្មោះ[redacted]សុភា អនុវត្តទោសក្នុងពន្ធនាគារបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់អនីតិជនទាំងបី ។ ហេតុនេះ គប្បីតុលាការផ្ដល់ស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ [redacted]ុភា ។

## <u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី</u>

**១-ផ្ដន្ទាទោស៖**

**១.១-ឈ្មោះ** [redacted]SUNDAY ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិនីហ្សេរីយ៉ា ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ៣ (**បី**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ៤០០.០០០.០០០ (**បួនរយលាន**) **រៀល** ។

**១.២-ឈ្មោះ**[redacted] **សុភា** ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ២ (**ពីរ**) **ឆ្នាំ** តែទោសនេះត្រូវព្យួរទាំងស្រុង តាមបញ្ញត្តិស្ដីពីការព្យួរទោសធម្មតានៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០០.០០០.០០០ (**មួយរយលាន**) **រៀល**

ពីបទ **ឆបោក** និង **សំអាតប្រាក់** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃច្បាប់ស្ដីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**២-រឹបអូសវត្ថុចាប់យក** និងទ្រព្យសម្បត្តិដូចខាងក្រោម៖

-ទូរស័ព្ទដៃម៉ាក Olitech ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។



Scanned with CamScanner

-ទូរស័ព្ទដៃម៉ាក SUMSUNG G8 PLUS ពណ៌ខៀវ ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។

-ខ្សែកលោហធាតុ ពណ៌លឿងចំនួន ០១ (មួយ) ខ្សែ ។

-នាឡិការដៃម៉ាក DIESEL ពណ៌ទឹកមាស ចំនួន ០១ (មួយ) គ្រឿង (មិនដំណើរការ) ។

៣-រឹបអូសប្រាក់សរុបចំនួន **៣០.៥៩៧,២៦$** (សាមសិបពាន់ និងប្រាំរយកៅសិបប្រាំពីរដុល្លារអាមេរិក ម្ភៃប្រាំមួយសេន) ដែលរក្សាទុកក្នុងគណនីធនាគារដោយក្នុងនោះ៖

-ប្រាក់ចំនួន **៣០.៥៤០,៥៥ $** (សាមសិបពាន់ ប្រាំរយសែសិបដុល្លារអាមេរិក និងហាសិបប្រាំសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ០០០៨០៨៦៦០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ដែលមានជនជាប់ចោទឈ្មោះ **OYINBOSON ENEOJO SUNDAY** ជាម្ចាស់គណនី ។

-ប្រាក់ចំនួន **៥៨,០៧$** (សែសិបប្រាំពីរដុល្លារអាមេរិក សូន្យប្រាំពីរ) បន្សល់ទុកនៅក្នុងគណនីធនាគាររបស់ជនជាប់ចោទឈ្មោះ **សុខ សុភា** ដោយក្នុងនោះប្រាក់ចំនួន ០,០៣ (សូន្យក្បៀស និងសូន្យបីសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ០០០៥១៤៣១០ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ប្រាក់ចំនួន ១៦,៣៧ (ដប់ប្រាំមួយដុល្លារអាមេរិក និងសាមសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ២០១០០១១០០០០២១៨៣១ ចេញដោយ **ធនាគារ ធនាគារ អ អេច ប៊ី** ប្រាក់ចំនួន ១០,០០$ (ដប់ដុល្លារអាមេរិក) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ៥៣៩០០២៩ ចេញដោយ **ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់** ប្រាក់ចំនួន ១១,៦៧$ (ដប់មួយដុល្លារអាមេរិក និងហុកសិបប្រាំពីរសេន) បន្សល់ទុកនៅក្នុងគណនីធនាគារលេខ ២៦០០២៣០០១៦២៦៨ ចេញដោយ **ធនាគារកម្ពុជាសាធារណៈ** និងប្រាក់ចំនួន ១០ $ (ដប់ដុល្លារអាមេរិក) បន្សល់ទុកក្នុងគណនីធនាគារដែលមានលេខ ០៨០០០០៩៥៣៨៥០ ចេញដោយ **ធនាគារសាខមប៉ែង** ។

-និងប្រាក់ចំនួន **៨.៦៥$** (ប្រាំបីដុល្លារអាមេរិក និងហុកសិបបួនសេន) ទៀតបន្សល់ទុកនៅក្នុងគណនីធនាគាររបស់ក្រុមហ៊ុនឈ្មោះ APPROVE GLOBAL CO., LTD ដែលមានគណនីលេខ ០០១២៥២៤០៤ ចេញដោយ **ធនាគារ វឌ្ឍនៈអាស៊ីចំកាត់** ។

**៤-ប្រគល់វត្ថុចាប់យក៖**

-លិខិតឆ្លងដែនលេខ A៥០២១០៤៤១ ចំនួន ០១ (មួយ) ក្បាល ។

-សៀវភៅការងារជនបរទេស ចំនួន ០១ (មួយ) ក្បាល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **SUNDAY** និងជនជាប់ចោទឈ្មោះ [redacted] **សុភា** និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រាក្រឡាបញ្ជី [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រាចៅក្រ[redacted]

**បានឃើញ**

ថ្ងៃ ពុធ ០៤ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ ពុធ ០៤ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner